# អ្នកនាំសារ
The Messenger

កាសែតចេញផ្សាយប្រចាំខែមីនា ឆ្នាំទី៤ ថ្ងៃទី០១-៣១ ខែមីនា ឆ្នាំ២០១១ លក់តម្លៃ ១000រៀល តែប៉ុណ្ណោះ លេខ ៤៣


Formation, Dialogue, Cooperation

មាតិកា




ទូរស័ព្ទចិនចាប់ផ្តើមវាយលុក.. ទំព័រ ៥





មាសបៃតងគឺជាគោលដៅថ្មី... ទំព័រ ៩





អ្នកជំនាញអក្សរសាស្ត្រ "ពាក្យ... ទំព័រ ១៧


## ទីផ្សារអង្ករ និងបញ្ហាប្រឈមរបស់កម្ពុជាដើម្បីធ្វើជាអ្នកនាំចេញដ៏សំខាន់



ស្រូវគឺជាធញ្ញជាតិយ៉ាងសំខាន់ដែលប្រជាជនខ្មែរផលិតបាន ។ ប៉ុន្តែដើម្បីឱ្យផលិតផលនេះអាចចូលរួមក្នុងការលើកស្ទួយជីវភាពរបស់ប្រជាពលរដ្ឋ ក៏ដូចជាសេដ្ឋកិច្ចជាតិទាំងមូលនោះ លុះត្រាតែមានទីផ្សារនាំចេញក្នុងតម្លៃខ្ពស់សមរម្យ ។ តើអ្វីជាបញ្ហាប្រឈមរបស់កម្ពុជាក្នុងការក្លាយខ្លួនជាអ្នកនាំចេញស្រូវដ៏សំខាន់? តើអ្វីជាការលំបាករបស់កសិករជាអ្នកផលិត? ទំព័រទី១០_១១




### អេម៉ានូអែល សំឡេងពីព្រះសហគមន៍កាតូលិក !

ភ្នំពេញ : FM 102.5 Mhz ម៉ោង២:00-៣:00 រាល់រសៀលថ្ងៃសុក្រ
បាត់ដំបង : FM 91.0 Mhz ម៉ោង ៧:៣0-៨:៣0 រាល់យប់ថ្ងៃសៅរ៍
សៀមរាប: FM 102.5 Mhz ១0:00-១១:00 រាល់ថ្ងៃសៅរ៍
កំពង់ធំ : FM 88.5 Mhz ម៉ោង ១២:៣0-១:៣0 ថ្ងៃសៅរ៍ថ្ងៃត្រង់
កំពង់ចាម : FM 100.5 Mhz ម៉ោង ៦:៣0-៧:00 យប់ថ្ងៃអាទិត្យ
ក្រុងព្រះសីហនុ : FM 107.5 Mhz ម៉ោង៥:00-៦:00 រសៀលថ្ងៃសៅរ៍
កំពត : FM 93.25 Mhz ម៉ោង ៥:00-៦:00 រសៀលថ្ងៃសៅរ៍

# រូបថតប្រចាំខែ



Photos : Sihanouk Ville



អបអរសាទរពិធីខួបកំណើតរបស់លោកអភិបាលអ៊ីវ  រ៉ាមូស  ថ្ងៃទី២៤  ខែកុម្ភៈ  ឆ្នាំ២០១១
ក្នុងគម្រប់ខួប៨៣  ឈានចូល  ៨៤ឆ្នាំ  និងខួបឆ្នាំទី៤៨  ទទួលអគ្គសញ្ញាតែងតាំងជាអភិបាល។
សូមព្រះជាម្ចាស់ប្រោសប្រទានដល់លោកនូវសុខភាពល្អបរិបូរ  កម្លាំងពលំមាំមួន
និងប្រាជ្ញាឈ្លាសវៃ  ដើម្បីនៅរួមប្រកាសដំណឹងល្អជាមួយព្រះសហគមន៍ប្រទេសកម្ពុជា។





## វិចារណកថា

# សេចក្តីថ្លែងការណ៍របស់ព្រះសហគមន៍កាតូលិកកម្ពុជា

ព្រះសហគមន៍កាតូលិកកម្ពុជាមានសេចក្តីសោកស្តាយជាខ្លាំងចំពោះការប្រយុទ្ធដោយប្រដាប់អាវុធក្នុងរយៈពេលប៉ុន្មានថ្ងៃកន្លងមកនេះនៅតំបន់ប្រាសាទព្រះវិហារ និងសូមរួមចំណែកក្នុងទុក្ខលំបាកនេះ ដែលជាទុក្ខលំបាករួមរបស់ជាតិយើងទាំងមូល និងរបស់មនុស្សជាតិ។

ព្រះសហគមន៍កាតូលិកកម្ពុជា សូមអញ្ជើញភាគីទាំងពីរឱ្យស្វែងរកសន្តិភាពតាមសេចក្តីពិត "ស្វែងរកសន្តិភាពតាមសេចក្តីពិត គឺអញ្ជើញមនុស្សទាំងអស់ឱ្យមានទំនាក់ទំនងគ្នាដោយចិត្តស្មោះដែលបង្កើតផលផ្លែ។ ស្វែងរកសន្តិភាពតាមសេចក្តីពិត គឺលើកទឹកចិត្តមនុស្សយើង ឱ្យស្វែងរកផ្លូវដើម្បីលើកលែងទោស និងសម្រុះសម្រួលគ្នា ឱ្យពិភាក្សាគ្នា ដោយមិនលាក់លៀមអ្វី និងដោយមានចិត្តស្មោះត្រង់នឹងពាក្យសន្យារបស់ខ្លួន" (សារដើម្បីសន្តិភាពឆ្នាំ ២០០៦ របស់ សម្តេចប៉ាបបេណេឌីតូទី១៦)។

ព្រះសហគមន៍កាតូលិកកម្ពុជា សូមអំពាវនាវដល់គ្រប់អង្គការសហគមន៍ជាតិ និងអន្តរជាតិទាំងអស់ សូមចូលរួមចំណែកតាមសមត្ថកិច្ច តាមគ្រប់រូបភាពដើម្បីបញ្ឈប់ជាបន្ទាន់នូវការប្រយុទ្ធដោយប្រដាប់អាវុធនេះ ដែលកើតនៅតំបន់ប្រាសាទព្រះវិហារដែលបណ្តាលឱ្យបាត់បង់នូវអាយុជីវិតដ៏មានតម្លៃរបស់មនុស្សបណ្តាលឱ្យប្រជាជនរងទុក្ខលំបាកយ៉ាងខ្លាំង និងដែលបានបំផ្លាញនូវទីសក្ការៈរបស់ប្រជាជន និងប្រាង្គប្រាសាទដែលជាបេតិកភណ្ឌដ៏មានតម្លៃរបស់មនុស្សជាតិនេះផង។

យើងខ្ញុំសូមអង្វរព្រះជាម្ចាស់ សូមព្រះអង្គប្រោសប្រទានសេចក្តីសុខសាន្តឱ្យកើតមានដល់ប្រទេសទាំងពីរ និងសូមឱ្យអស់លោក អ្នកដឹកនាំនៃប្រទេសទាំងពីរ ខិតខំដោះស្រាយបញ្ហាវិវាទនានា ដោយសន្តិវិធី ព្រមទាំងជៀសវាងមិនឱ្យមានការបង្ហូរឈាមតទៅទៀត។

**រាជធានី ភ្នំពេញ ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១១**

**តំណាងព្រះសហគមន៍កាតូលិកកម្ពុជា**

**លោកអភិបាលសុខកុមារ អូលីវីយេ ឃ្មីតអីស្មែរ**

**កម្មវិធី ពន្លកថ្មី**
**ជាកម្មវិធីវិទ្យុថ្មីមួយរបស់**
**ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក។**
**កម្មវិធីនេះផ្តោតលើពលកម្មកុមារ**
**និងបន្ទារការកេងប្រវ័ញ្ច លើកុមារ**
**ដែលសហការជាមួយវិទ្យុសម្លេង**
**ប្រជាធិបតេយ្យ VOD មានផ្សាយ**
**នៅរាល់ ថ្ងៃច័ន្ទ ម៉ោង ៤.៥ រសៀល**
**ផ្សាយនៅ FM 106.5 MHz ។**

## កម្មវិធីវិទ្យុព្រះសហគមន៍កាតូលិក

**អ្នកចូលរួមកម្មវិធីអេម៉ាទូអែល "សម្លេងពីព្រះសហគមន៍កាតូលិក" ខែមីនា**

-ថ្ងៃអាទិត្យទី០៦ ខែមីនា ឆ្នាំ ២០១១ អាទិត្យទី៩ ក្នុងរដូវធម្មតា : ចូលរួមដោយលោកបូជាចារ្យម៉ែត វិន័យ អ្នកទទួលខុសត្រូវព្រះសហគមន៍កាតូលិកកំពង់ធំ ភូមិភាគបាត់ដំបង។

-ថ្ងៃអាទិត្យទី១៣ ខែមីនា ឆ្នាំ២០១១ អាទិត្យទី១ ក្នុងរដូវសែសិបថ្ងៃ : ចូលរួមដោយលោកបូជាចារ្យឌូស៍ មកពីព្រះសហគមន៍កាតូលិកចំការទៀង ភូមិភាគភ្នំពេញ។

-ថ្ងៃអាទិត្យទី២០ ខែមីនា ឆ្នាំ២០១១ អាទិត្យទី២ ក្នុងរដូវសែសិបថ្ងៃ : ចូលរួមដោយលោកបូជាចារ្យទម្លាប់ សុផល ទទួលខុសត្រូវព្រះសហគមន៍កាតូលិកខ្មែររមាស ភូមិភាគព្រះសហគមន៍កាតូលិកបាត់ដំបង។

-ថ្ងៃអាទិត្យទី២៧ ខែមីនា ឆ្នាំ២០១០ អាទិត្យទី៣ ក្នុងរដូវសែសិបថ្ងៃ : ចូលរួមដោយលោកហៃរណាន់ ពីនីឡា អ្នកទទួលខុសត្រូវព្រះសហគមន៍កាតូលិកពោធិ៍សាត់។

# ការប្រកួតជ្រើសរើសជើងឯកតេក្វាន់ដូនៅបាត់ដំបង

ការប្រកួតតេក្វាន់ដូជ្រើសរើសជើងឯកមេគុណលើកទី១ របស់សហគមន៍តេក្វាន់ដូបាត់ដំបង(WTF) ប្រចាំឆ្នាំ២០១១ គឺបានធ្វើឡើងនៅព្រះសហគមន៍បាត់ដំបងកាលពីថ្ងៃទី១៨ កុម្ភៈ ឆ្នាំ២០១១។

លោកឆេ យុងសុខ គណៈមេប្រយោគដាក់ពិន្ទុ និងជាប្រធានក្លិបនៅភ្នំពេញ បានមានប្រសាសន៍ថា : "នេះជាការប្រកួត(ភូមសេ) ដែលយើងគិតតាមអាយុដើម្បីរើតចំណងមិត្តភាពនិងការបង្ហាញស្នាដៃរវាងក្រុមនីមួយៗ"។

នេះក៏ជាការប្រកួតលើកទីមួយដែលធ្វើនៅព្រះសហគមន៍កាតូលិកខេត្តបាត់ដំបង ដោយមានការអញ្ជើញចូលរួមពីសំណាក់មេប្រយោគដែលមកពីប្រទេសកូរ៉េ ព្រមទាំងអភិបាលរងក្រុងបាត់ដំបង និងលោកបូជាចារ្យតូតែត ថែមទាំងគ្រូបង្ហាត់តេក្វាន់ដូជាច្រើនរូបទៀត។

កុមារាសុខ សារឿន អាយុ ១២ឆ្នាំ មកពីក្លិបកាតូលិកក្នុងខេត្តបាត់ដំបង បាននិយាយថា : "ខ្ញុំហាត់កីឡាតេក្វាន់ដូនេះ ជាងមួយឆ្នាំកន្លះហើយ។ នេះជាលើកទីមួយដែលបានបញ្ចេញនូវសមត្ថភាពក្នុងការប្រកួតយកមេដាយ"។


Photo : Rithy Rath

អ្នកប្រកួតមកពីខេត្តក្រុង៥និងក្លិប៩ ដូចជាក្លិបភ្នំពេញ ក្លិបកាតូលិក ក្លិបឥន្ទ្រីទេព ក្លិបថាស ក្លិបរ៉ុងក្វាង ក្លិបសាវ៉ុអាណាន់ ក្លិបពូជប៊ិចលី ក្លិបប៉ោយប៉ែត និងក្លិបណែមស៊ីគង់។ **អាង ឫទ្ធីរដ្ឋ**

# សេដ្ឋកិច្ច

## ច្រករបៀងសេដ្ឋកិច្ចនាំមកនូវការអភិវឌ្ឍន៍ដល់កម្ពុជា

**ខាន់ ភីរម្យ**

សេដ្ឋកិច្ចវិទូរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ប្រចាំនៅក្នុងប្រទេសកម្ពុជាបានអះអាងប្រកបដោយសុទិដ្ឋិនិយមថា ច្រករបៀងសេដ្ឋកិច្ចភាគខាងត្បូងដែលជាបណ្ដាញផ្លូវថ្នល់មួយតភ្ជាប់កម្ពុជា ទៅនឹងបណ្ដាប្រទេសនៅក្នុងតំបន់នឹងនាំមកនូវការអភិវឌ្ឍន៍ និងការកាត់បន្ថយភាពក្រីក្រនៅ ២១ខេត្ត និងរាជធានី ។


Photo : DR

លោកពូទូ កាម៉ាយ៉ានា តំណាងធនាគារអភិវឌ្ឍន៍អាស៊ីប្រចាំនៅប្រទេសកម្ពុជា មានប្រសាសន៍ថា ច្រករបៀងសេដ្ឋកិច្ចភាគខាងត្បូងនឹងក្លាយជាច្រករបៀងផ្លូវគមនាគមន៍ដ៏សំខាន់ ដែលនឹងផ្ដល់ប្រយោជន៍ដល់ការអភិវឌ្ឍន៍និងកាត់បន្ថយភាពក្រីក្រដល់ប្រជាពលរដ្ឋកម្ពុជានៅក្នុងខេត្ត និងរាជធានីទាំង២១ ក្នុងប្រទេសតាមរយៈការតភ្ជាប់ ប្រទេសកម្ពុជាទៅនឹងបណ្ដាប្រទេសនៅក្នុងតំបន់មហាអនុតំបន់ទន្លេមេគង្គ ។

លោកមានប្រសាសន៍បញ្ជាក់ថា : "ច្រករបៀងសេដ្ឋកិច្ចភាគខាងត្បូង ដែលត្រូវបានគេកសាងឆ្លងកាត់ ២១ខេត្ត នៅក្នុងប្រទេសកម្ពុជា គឺជាសក្ដានុពលមួយដ៏ចម្បងដែលនឹងបង្កើននូវកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍន៍នៅក្នុងប្រទេសកម្ពុជា តាមរយៈការជំរុញការផ្លាស់ប្ដូរពាណិជ្ជកម្ម" ។

លោកភីធ័រ ប្រ៊ីមប៊ល ជាអ្នកសេដ្ឋកិច្ចជាន់ខ្ពស់របស់ធនាគារអភិវឌ្ឍន៍អាស៊ីប្រចាំនៅក្នុងប្រទេសកម្ពុជាបានឱ្យដឹងថា ទីក្រុងនានាតាមបណ្ដោយផ្លូវជាតិធំៗ នៅក្នុងច្រករបៀងនឹងបានរីកដុះដាលជាក់ស្ដែងដូចជាទីក្រុងកំពង់ឆ្នាំង ពោធិ៍សាត់ និងទីក្រុងកំពង់ធំជាដើម ។

បើតាមការអះអាងរបស់លោកភីធ័រ ប្រ៊ីមប៊ល បណ្ដាខេត្ត និងរាជធានីទាំង២១ នឹងភ្ជាប់ទៅកាន់ផ្នែកផ្សេងៗ ក្នុងបណ្ដាប្រទេស នៅមហាអនុតំបន់ទន្លេមេគង្គ ។ នៅពេលនោះ វាក៏នឹងជំរុញឱ្យវិស័យផ្សេងៗ គឺដូចជាទេសចរណ៍ ពាណិជ្ជកម្ម ដឹកជញ្ជូន កសិកម្ម ថាមពលវិនិយោគទុន ធនធានមនុស្ស និងសុខភាពជាដើម បានរីកចម្រើន ។

### ច្រករបៀងសេដ្ឋកិច្ចភាគខាងត្បូងអាចជួយអភិវឌ្ឍដល់ប្រជាពលរដ្ឋកម្ពុជា ១១លាន នាក់

ធនាគារអភិវឌ្ឍន៍អាស៊ីបានអះអាងថា នៅក្នុងចំណោមប្រជាពលរដ្ឋបួនប្រទេសដែលអនុវត្តនូវគម្រោងច្រករបៀង សេដ្ឋកិច្ចភាគខាងត្បូងនេះ មានប្រជាពលរដ្ឋសរុបចំនួន ៤០,៥លាននាក់ នៅក្នុងនោះកម្ពុជា មានប្រជាពលរដ្ឋប្រមាណជា ១១,៩លាននាក់។

បណ្ដាប្រទេស៤ ដែលស្ថិតនៅក្នុងគម្រោងនេះមានកម្ពុជា វៀតណាម ឡាវ និងថៃ។ ប្រភពដដែលនោះបានឱ្យដឹងថា នៅក្នុងប្រទេសវៀតណាមមានប្រជាពលរដ្ឋប្រមាណជា ១៦,២លាននាក់ ថៃមានចំនួន ៩,៨លាននាក់ ហើយ ឡាវ មានចំនួន ២,៣លាននាក់ ដែលបានផលពីគម្រោង ដែលបណ្ដោយប្រមាណសរុប ប្រមាណ ៣០៤,៦៨១គម² នៅក្នុងនោះ កម្ពុជាមានទំហំប្រមាណជា ៤៩% ឡាវ ២៧% វៀតណាមចំនួន ១៥,៥% ហើយថៃវិញនោះ មានចំនួន ៨,៥%។

លោកក៏បានឱ្យដឹងថា ច្រករបៀងសេដ្ឋកិច្ចភាគខាងត្បូង គឺជាគម្រោងដែលមានអាទិភាពមួយនៅក្នុងចំណោមគម្រោងចំនួន៩៥ ដែលមានតម្លៃចំនួន ១១,៦ពាន់លានដុល្លារ ដែលគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី ។

# សុខភាព

## ចិញ្ចឹមកូនដោយទឹកដោះគោលុះត្រាតែគ្មានជម្រើសប្រើទឹកដោះម្ដាយ

**ជាត សំភី**

ការចិញ្ចឹមកូនឱ្យមានសុខភាពល្អ និងភាពវៃឆ្លាតជាក្ដីប៉ងប្រាថ្នារបស់មាតាបិតាគ្រប់រូប ។ ប៉ុន្តែចុះបើម្ដាយមិនបាន បំបៅដោះកូន ឬមិនអាចបំបៅដោះកូន? តើគេត្រូវធ្វើដូចម្ដេច?


Photo : Rithy

លោកវេជ្ជបណ្ឌិតហែម សុខហន នៃមន្ទីរពេទ្យកុមារជាតិរាជធានីភ្នំពេញ ធ្វើការណែនាំវិធីសាស្ត្រមួយចំនួន បើជៀសពុំរួចពីការបំបៅដោយទឹកដោះគោ ពោលគឺ គេត្រូវមានដបពី៦ ទៅ១០ដប ដើម្បីផ្លាស់ប្ដូរ ។ ដបត្រូវសោរ ឬចំហុយ សម្លាប់មេរោគ ។ បន្ទាប់មកត្រូវឆុងទឹកដោះគោជាមួយទឹកដាំពុះ ១០០អង្សារសេ ។ តែទឹកនោះត្រូវទុករយៈពេលពី ១០ទៅ១៥នាទីសិន ឱ្យវាធ្លាក់ចុះមកនៅត្រឹម៧០អង្សារសេ ទើបវិតាមីនមិនងាប់ ។ ប៉ុន្តែបើឆុងទឹកដោះគោជាមួយទឹកត្រជាក់ធ្វើឱ្យខ្លាញ់មិនលាយ ។ ចូរឆុងទឹកដោះគោជាមួយនឹងដបកែវ ពីព្រោះការដាក់ទឹកក្ដៅទៅក្នុងដបជ័រ នឹងអាចចេញសារធាតុពុលដែលផ្ដល់ផលពិបាកទៅថ្ងៃក្រោយ ។

លោកវេជ្ជបណ្ឌិត មានប្រសាសន៍ទៀតថា តាមធម្មតា ម្ដាយមិនអាចបំបៅកូនបិតក្នុងករណីដូចជាម្ដាយ មានមេរោគអេដស៍ ម្ដាយធ្វើការវះកាត់ ជំងឺផ្សេងៗទៀត ឬគាត់ចេញទៅធ្វើការងារនៅទីឆ្ងាយ ដែលមិនមានពេលបំបៅដោះកូន ។

ទោះបីជាយ៉ាងណា លោកវេជ្ជបណ្ឌិត អំពាវនាវឱ្យមាតាបំបៅកូននឹងទឹកដោះ ហើយបំបៅនឹងទឹកដោះសុទ្ធយ៉ាងតិច ៦ខែ ។ បើធ្វើយ៉ាងនេះកូនគាត់នឹងមានការវិវត្តន៍រីកធំធាត់ល្អ មានសុខភាពល្អគ្មានជំងឺដម្កាត់ និងឈ្លាសវៃ និងម្យ៉ាងវិញទៀត ម្ដាយនិងកូន ក៏មានចំណងមេត្រីភាពល្អ ព្រមជាមួយនិងការចំណេញលុយកាក់ និងពេលវេលា ក្នុងការទិញទឹកដោះគោមកឆុងផង ។



Photo : V. Sombath

# ទូរស័ព្ទចិនចាប់ផ្ដើមវាយលុកទឹកចិត្តយុវជនជនបទ

**ខាន់ ភីរម្យ**

ដោយមានតម្លៃយ៉ាងថោក និងសម្បូរទៅដោយកម្មវិធីដ៏ប្លែកៗជាច្រើន ទូរស័ព្ទមួយប្រភេទដែលយុវជននិយមដាក់ឈ្មោះថា ទូរស័ព្ទចិន បានកំពុងតែវាយលុកទឹកចិត្ត និងជំរុញឱ្យយុវជននៅជនបទប្រើប្រាស់កាន់តែច្រើនឡើងៗ។

យុវជនជា រតនា អាយុ ២២ឆ្នាំ ជាជាងសំណង់ បានអះអាងថា ជាមួយនឹងតម្លៃត្រឹមតែ ៤៥ដុល្លារ រូបគេអាចរកទិញ និងទទួលបាននូវទូរស័ព្ទមួយដែលអាចដាក់ស៊ីម២ ហើយមានទូរទស្សន៍មើល និងស្ដាប់ចម្រៀង ពេលធ្វើការបានថែមទៀតផង។

ទូរស័ព្ទដែលរតនាកំពុងតែប្រើប្រាស់នោះ គឺមិនដឹងថា ជាទូរស័ព្ទម៉ូដែលណាមួយនោះទេ។ នៅលើទូរស័ព្ទនោះ គេគ្រាន់តែដាក់អក្សរថា HTC តែប៉ុណ្ណោះ។ តែជាមួយនឹងអេក្រង់ទំហំប្រមាណប៉ុនបាតដៃ ទូរស័ព្ទនោះអាចឱ្យរតនាដាក់បានស៊ីម ពីរ ថាច់ស្គ្រីន (Touch Screen) ហើយអាចនឹងផ្លាស់ប្ដូរចុះឡើង មានទូរទស្សន៍ មានកម្មវិធីMP3 ដែលអាចឱ្យរតនាមិនត្រឹមតែអាចស្ដាប់ចម្រៀងបានទេ តែអាចឱ្យគាត់មើលទូរទស្សន៍ ឬខារ៉ាអូខេ ឬលេងហ្គេមបានថែមទៀតផង។

រតនាក៏បានបញ្ជាក់ឱ្យដឹងថា: "ខ្ញុំគ្មានលុយទិញអាថ្លៃដូចគេទេ។ ដូច្នេះខ្ញុំប្រើអាហ្នឹងស្រួល។ តម្លៃវាថោក ហើយកាន់ទៅ មើលដូចជាទូរស័ព្ទគេថ្លៃៗដែរ ពេលដើរលេងអីឡូយដែរតើ"។

មន្ត្រីរាជការវ័យក្មេង មួយរូបបានអះអាង រូបលោកក៏ជាអ្នកដែលកំពុងតែប្រើប្រាស់ទូរស័ព្ទចិនផងដែរ។ លោកបញ្ជាក់ថា : "គ្មានអ្នកណាស្គាល់ម៉ាក ឬម៉ូដែលវាទេ តែអាថ្មីខ្ញុំកំពុងតែប្រើនេះដូចជា IPhone4 តម្លៃជិត ១000ដុល្លារដែរ"។

មន្ត្រីរាជការរូបនោះ បានឱ្យដឹងថា: "បើសិនជាមិនកាន់នឹងដៃ រួចយកមកពីពិនិត្យពិច័យឱ្យច្បាស់ទេ ឃើញមួយភ្លែត គ្មាននរណាម្នាក់ដឹងថា ខ្ញុំប្រើប្រាស់របស់ចិននោះទេ។ មើលពីក្រៅរាងដូចរបស់គេសុទ្ធមែនទែន តែកុំសួរពីតម្លៃរបស់វាហៅមិនឮទេ។ តម្លៃរបស់វាត្រឹមតែ ៥៥ដុល្លារប៉ុណ្ណោះ"។

សព្វថ្ងៃនេះ ទូរស័ព្ទដែលគេអះអាង ហើយដាក់ឈ្មោះថា ទូរស័ព្ទចិនមានច្រើនម៉ូដែលណាស់ហើយ មានរូបរាងទាន់សម័យដូចជាបណ្ដាទូរស័ព្ទដៃពេញនិយមទាំងឡាយមាននៅលើទីផ្សារ។

លោកជា សុខឃៀង អាជីវករលក់ទូរស័ព្ទមួយរូប បានអះអាងថា តាមពិតទៅ ទូរស័ព្ទដែលកំពុងតែប្រើប្រាស់នៅក្នុងប្រទេសកម្ពុជានាពេលសព្វថ្ងៃនេះសឹងតែ៩0%ហើយផលិតនៅក្នុងប្រទេសចិន។ ប៉ុន្តែចំពោះទូរស័ព្ទ ដែលគេៗនិយមហៅថា ទូរស័ព្ទចិននោះជាទូរស័ព្ទដែលគ្មានម៉ាកអ្វីពិតប្រាកដ គ្មានម៉ូដែលច្បាស់លាស់ និងគ្មានសេរី។ ពួកវាវាយលុកទីផ្សារម្ដងម្កាល ខណៈដែលទូរស័ព្ទផ្សេងៗ ទៀតគេមានជាសេរីមានម៉ូដែលរបស់គេច្បាស់លាស់ដូចជាណូគា Nokia ជាដើម។

លោកក៏បានឱ្យដឹងថា ទូរស័ព្ទនេះលក់ដាច់ខ្លាំងជាពិសេសអតិថិជនរបស់វា គឺជាយុវជនក្មេងៗ និងកម្មករដោយសារតែវាធូថ្លៃ ហើយមានកម្មវិធីទាន់សម័យជាច្រើន ហើយអ្វីដែលធ្វើឱ្យគេនិយមនោះ គឺរាងរៅរបស់ពួកវា ដែលអាចយកបន្លំជាមួយនឹងទូរស័ព្ទដែលថ្លៃៗបាន។

លោកបានឱ្យដឹងទៀតថា តម្លៃរបស់ពួកវាមានចាប់ពី ៣0ដុល្លារ រហូតដល់ទៅជាង១00ដុល្លារ។ ហើយគេធានាត្រឹមតែ ៣ខែ ទេ។

លោកបានបន្តទៀតថា ទូរស័ព្ទចិននេះ សព្វថ្ងៃមានម៉ូតច្រើនណាស់ តែភាគច្រើនវាមកមួយឆាវៗ ពេលលក់អស់ គឺអស់ហើយ លើកក្រោយមកមានម៉ូតថ្មី។ បើយើងស្រលាញ់អាម៉ូតចាស់ គឺពិបាករក ហើយទូរស័ព្ទនេះភាគច្រើន គេមិនលក់និងដូរ បានទេ។លោកបញ្ជាក់ថា: "តែទិញហើយគឺទិញហើយ មិនអាចលក់ដូរម៉ូតដូច **Nokia** វិញបានទេ"។

# ត្រូវមានការប្រុងប្រយ័ត្នបំផុតចំពោះថ្នាំពុលកសិកម្ម

**ជាត សំភី**



Photo : CEDAC

"ថ្នាំពុលកសិកម្មផ្សំឡើងពីសារធាតុគីមីទោល ឬសំយោគ ដែលគេផលិតឡើងដើម្បីបណ្តេញ ឬក៏កម្ចាត់កត្តាចង្រៃ ដែលបំផ្លាញដំណាំ ឬផលិតផលកសិកម្មផ្សេងៗ។ គេអាចរាប់ថ្នាំពុលកសិកម្មជាថ្នាំពុលសម្លាប់សត្វល្អិត រុក្ខជាតិចង្រៃ និងពពួកបាក់តេរី..."។ នេះបើតាមប្រសាសន៍របស់អ្នកជំនាញ។

បើតាមប្រសាសន៍របស់លោកគាម មករាឌី ជានាយកកម្មវិធីបរិស្ថាន និងសុខភាពនៃមជ្ឈមណ្ឌលសិក្សា និងអភិវឌ្ឍន៍កសិកម្មកម្ពុជា ក៏បានឱ្យដឹងថា ការប្រើប្រាស់ថ្នាំពុលកសិកម្មនៅប្រទេសកម្ពុជានាសព្វថ្ងៃនេះគឺមានលក្ខណៈមិនអាចគ្រប់គ្រងបាន ដោយសារយើងមិនអាចគ្រប់គ្រងអ្នករកស៊ីនាំចូលថ្នាំពុលកសិកម្មបាន។ នៅពេលគេនាំចូល គេតែងផ្សព្វផ្សាយថា ផលិតផលិតផលរបស់គេល្អ។ហើយកសិករក៏ប្រើប្រាស់តៗគ្នា ដែលនាំឱ្យគ្រោះថ្នាក់។

លោកគាម មករាឌីគូសបញ្ជាក់ថា: "ការបំផ្លាញរបស់កត្តាចង្រៃ ដូចជាសត្វល្អិត ស្មៅ បាក់តេរី... ទាល់តែឈានដល់ដំណាក់កាលមួយ ដែលមិនអាចទប់ទល់ និងការពារបាន ទើបអ្នកជំនាញកសិកម្មណែនាំឱ្យប្រើប្រាស់ថ្នាំពុល ហើយការប្រើប្រាស់ថ្នាំទៀតសោត គឺទាល់តែធ្វើទៅតាមកម្រិតបច្ចេកទេសខ្ពស់បំផុតទើបបាន"។

លោកគាម មករាឌីបានឱ្យដឹងទៀតថា មិនទាន់មានការសិក្សាច្បាស់ថា ការប្រើប្រាស់ថ្នាំពុល នៅប្រទេសកម្ពុជាមាននូវកម្រិតណានោះទេ។ តែគេគ្រាន់តែដឹងថា ការប្រើប្រាស់ថ្នាំពុលផ្សំពីរុក្ខជាតិគឺមានពី១០ ទៅ១៥% ប៉ុណ្ណោះ។ លោកគាម មករាឌីរៀបរាប់ដែរថា ថ្នាំពុលកសិកម្មនេះអាចធ្វើឱ្យប៉ះពាល់ដល់សុខភាពមនុស្ស សត្វ និងបរិស្ថាន។ ការប៉ះពាល់លើសុខភាព ទីមួយ គឺអ្នកទទួលសារធាតុពុលនៅក្នុងបរិមាណដ៏ច្រើននិងរយៈពេលខ្លី។ គាត់អាចឈឺក្បាល វិលមុខ ឈឺសាច់ដុំ ផ្សារភ្នែក ធឹងធោង ឬបើក្នុងករណីធ្ងន់ធ្ងរគាត់អាចសន្លប់បាត់បង់ស្មារតី ឬអាចស្លាប់បាន។ ទីពីរ "ការពុលរ៉ាំរ៉ៃ" ជនរងគ្រោះស្រូបយកជាតិពុលបន្តិច ម្តងៗ ដែលអាចសន្សំនៅក្នុងរាងកាយរហូតដល់អាចធ្វើឱ្យកើតជំងឺសរសៃប្រសាទ តម្រងនោមថ្លើម ឬជាជំងឺមហារីកផង នេះបើតាមការសិក្សាថ្មីៗ។

ចំណែកការប៉ះពាល់បរិស្ថាន គឺថ្នាំពុលធ្វើឱ្យខូចខាតដល់បរិស្ថានជីវចម្រុះក្នុងធម្មជាតិដូចជា ធ្វើឱ្យកខ្វក់ទឹក ឬបំផ្លាញដល់សត្រូវរបស់កត្តាចង្រៃ។

លោកគាម មករាឌី បញ្ជាក់ថាអ្នកប្រឈមមុខនឹងថ្នាំពុលកសិកម្មសំខាន់ៗ គឺមានកសិករជាម្ចាស់ អ្នកស៊ីឈ្នួលបាញ់ថ្នាំ និងអ្នកបរិភោគ...។

ដោយសារតែ ផលប៉ះពាល់ដូច្នេះ ទើបអង្គការជំនាញកសិកម្មនានា និងរាជរដ្ឋាភិបាលតែងលើកទឹកចិត្តឱ្យប្រជាកសិករប្រើប្រាស់នូវវិធានការចម្រុះការពារផលិតផលកសិកម្មរបស់គាត់។

បរិស្ថាន

## ព្រះសហគមន៍កោះរការអប់រំប្រជាពលរដ្ឋឱ្យទប់ស្កាត់មហន្តរាយ

"អ្នកភូមិកោះរកា ខេត្តកំពង់ចាម កំពុងតែប្រឈមមុខនឹងគ្រោះធម្មជាតិ។ ព្រះសហគមន៏ក៏កំពុងតែជំរុញកម្មវិធីបន្សាំនឹងបម្រែបម្រួលអាកាសធាតុដើម្បីទប់ស្កាត់ផលប៉ះពាល់ដល់ប្រជាជនទូទៅ"។ នេះបើតាមការអះអាងរបស់លោកស៊ន វ៉ែន មន្ត្រីកម្មវិធីអភិវឌ្ឍន៍របស់ព្រះសហគមន៏កោះរកា ភូមិភាគកំពង់ចាម។

លោកស៊ន វ៉ែន បានឱ្យដឹងថា ប្រជាជនភូមិនេះភាគច្រើនជាកសិករដាំដំណាំ។ ប៉ុន្តែប៉ុន្មានឆ្នាំចុងក្រោយនេះរបរ របស់ពួកគាត់បានរងគ្រោះ នឹងបម្រែបម្រួលអាកាសធាតុជាបន្តបន្ទាប់ ដូចជារាំងស្ងួត និងសត្វល្អិតចង្រៃជាដើម។

ជាពិសេស លោកស៊ន វ៉ែន បានបង្ហាញនូវក្តីកង្វល់របស់លោក ក៏ដូចជាប្រជាកសិករអំពីបញ្ហាទឹកទន្លេដែលចេះតែស្រកពីមួយឆ្នាំទៅមួយឆ្នាំ។ លោកស៊ន វ៉ែន បានបន្តឱ្យដឹងថា បញ្ហាកង្វះទឹកនេះនឹងមានផលប៉ះពាល់ខ្លាំងជាងគេចំពោះផលដំណាំផ្លែជាពិសេសផ្លែត្រសក់ និងដំណាំដទៃទៀត។

ដូចនេះដោយសារបញ្ហានេះ ព្រះសហគមន៏បានសម្រេចរៀបចំនូវកម្មវិធីមួយចំនួនដើម្បីបន្សាំ។

លោកសេវ៉ាល់ បូជាចារ្យ មានប្រសាសន៏ថា បម្រែបម្រួលអាកាសធាតុគឺជាបញ្ហាទាំងអស់គ្នា។ ដូច្នេះព្រះសហគមន៏យកចិត្តទុកដាក់បន្សាំនឹងបញ្ហានេះ។ លោកបន្តថា យើងបានរៀបចំកម្មវិធីអប់រំអំពីវិធីការពារដំណាំប្រឆាំង នឹងសត្វល្អិតចង្រៃ ផលប៉ះពាលនៃការប្រើប្រាស់ថ្នាំគីមី និងវិធីសាស្ត្រក្នុងការធ្វើជីកំប៉ុស្ដិ៍។ លើសពីនេះ យើងមានរៀបចំជាបណ្ណាល័យកសិកម្មមួយសម្រាប់កសិករបានស្វែងយល់ផងដែរ ។

លោកបូជាចារ្យបន្តថា ក្រៅពីកម្មវិធីទាំងអស់នេះព្រះសហគមន៏កោះរការក៏មានផ្តល់ទុន និងដីទំហំប្រមាណកន្លះហិចតា ដើម្បីផ្តល់ឱ្យកសិករក្រីក្រដែលគ្មានដីធ្លីធ្វើចំការ។ យើងបានអនុវត្តកម្មវិធីចំការចំនួន៥គ្រួសារ ដែលអាចឱ្យពួកគាត់ទទួលបានចំណូលសមរម្យ។

**ខាន់ ភីរម្យ**

# ព្រះសហគមន៍កាតូលិក

## ព្រះសហគមន៍កម្ពុជាផ្តល់ក្តីសង្ឃឹមសម្រាប់ជនក្រីក្រទទួលបានការព្យាបាល

**ជាត សំភី**



Photos : P. Samphy

បងស្រីនៅមណ្ឌលថែទាំសុខភាពសន្តយ៉ូសែបកំពុងនាំអ្នកជំងឺលេងកំសាន្តដើម្បីសម្រួលផ្លូវចិត្តគាត់ឱ្យឆាប់ជាពីជំងឺ

មានប្រជាជនប្រមាណជា ២០០នាក់ បានមកស្នាក់នៅជារៀងរាល់ខែ នៅក្នុងមណ្ឌលថែទាំសុខភាពមួយកន្លែងដែលមានទីតាំងស្ថិតក្នុងព្រះសហគមន៍សន្តយ៉ូសែប នៅក្រុងភ្នំពេញ ដើម្បីទទួលការព្យាបាលជំងឺគ្រប់ប្រភេទរបស់ពួកគាត់ ។

មណ្ឌលថែទាំសុខភាព ដែលគេហៅថា មណ្ឌលសន្តយ៉ូសែប ត្រូវបានស្ថាបនាឡើង ក្រោមគំនិតផ្តួចផ្តើមរបស់លោកអភិបាលអេមីលដេតម្ប ចាប់តាំងពីពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៩០ ។

មណ្ឌលនេះស្ថិតនៅក្នុងកម្មវិធីសកម្មភាពថែទាំសុខភាពរបស់ព្រះសហគមន៍កាតូលិកនៅភូមិភាគភ្នំពេញក្រោមការដឹកនាំរបស់លោកអភិបាល សុខកុមារ អូលីវីយេ ជ្មិតអឺស្លែរ ។

មណ្ឌលសន្តយ៉ូសែ និងសន្តីអេលីសាប៊ែត ដែលនៅខាងត្បូងរាជធានីភ្នំពេញ និងបង្កើតឡើងតាំងពីឆ្នាំ២០០៧ ដើម្បីទទួលអ្នកជំងឺដែលស្នាក់នៅយូរស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់ពីបងស្រី ប៉ោឡា ម៉ៃអូឃី ប្រធានគណៈកម្មាធិការសកម្មភាពសុខភាពនៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ ។

អ្នកស្រីអ៊ុន លីម អ្នកជំងឺសន្លាក់ឆ្អឹង អាយុ ៥៦ឆ្នាំ ដែលទើបនឹងមកពីភូមិមួយនៅស្រុកជុំគីរី ខេត្តកំពត បានមានប្រសាសន៍ឱ្យដឹងថា: "ប្រសិនបើខ្ញុំមិនបានមកទីនេះទេ ខ្ញុំប្រហែលជាមិនរស់ទេដោយសារខ្ញុំគ្មានលុយ ។ ខ្ញុំសូមអរគុណដល់លោកបូជាចារ្យម្នាក់ដែលបញ្ជូនខ្ញុំមកទីនេះ" ។

អ្នកស្រីបន្ថែមថា : "ពេលនេះ ខ្ញុំមានអារម្មណ៍ប្រសើរគ្រាន់បើហើយពីព្រោះខ្ញុំបានទទួលភាពកក់ក្តៅ និងការលើកទឹកចិត្តពីអ្នកថែទាំ" ។

បងស្រីប៉ោឡា ម៉ៃអូឃី ប្រធានគណៈកម្មាធិការសកម្មភាពសុខភាពនៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ បានមានប្រសាសន៍ឱ្យដឹងថា ព្រះសហគមន៍នានានៅក្នុងប្រទេសបានបញ្ជូនអ្នកជំងឺមកឱ្យយើង ។ ភាគច្រើនពួកគេគឺជាកសិករក្រីក្រ និងគ្មានសាច់ញាតិ ។ នៅពេលឈឺពួកគាត់មានការវង្វេង មិនដឹងថាត្រូវធ្វើដូចម្តេច? និងត្រូវព្យាបាលនៅទីណា ? អ៊ីចឹងហើយទើបបានជាពួកគាត់ក៏ត្រូវបានបញ្ជូនមកទីនេះ ។

បងស្រីបន្ថែមថា: "យើងចង់ផ្តល់ក្តីសង្ឃឹម ការលើកទឹកចិត្ត និងសេចក្តីស្រឡាញ់ដល់ពួកគាត់" ។

បើតាមប្រសាសន៍របស់បងស្រីប៉ោឡា ម៉ៃអូឃី អ្នកជំងឺត្រូវបញ្ជូនទៅកាន់ពេទ្យរដ្ឋដើម្បីទទួលការព្យាបាល ។ ប៉ុន្តែមណ្ឌលចេញថ្លៃចំណាយសម្រាប់ពួកគេលើ អាហារ ទីស្នាក់អាស្រ័យ ទឹកភ្លើង និងថ្នាំពេទ្យ-ល- ។ មណ្ឌលគ្រាន់តែសុំឱ្យពួកគាត់ជួយចេញវិភាគទានតាមលទ្ធភាពប៉ុណ្ណោះ ។

អ្នកស្រីឈឹម សយ អ្នកថែទាំអ្នកជំងឺអាយុ ៥២ឆ្នាំបានមានប្រសាសន៍ឱ្យដឹងថា អ្នកជំងឺភាគ ច្រើនគឺមកពីជនបទឆ្ងាយដាច់ស្រយាល ។ ពួកគាត់មានជីវភាពក្រីក្រ ហើយពួកគាត់រស់នៅដោយខ្វះអនាម័យ ។ ពួកគាត់គ្មាននូវអាហារដែលមានប្រូតេអ៊ីនគ្រប់គ្រាន់ដើម្បីបរិភោគ ។ ដូច្នេះពួកគាត់ងាយឆ្លងនូវជំងឺផ្សេងៗ ដែលទាក់ទងនឹងបញ្ហាអនាម័យ ។ អ្នកស្រីបានបន្ថែមថា : "ទីនេះ! យើងបង្រៀន ពួកគាត់ពីការរស់នៅដោយមានអនាម័យ និងការបរិភោគទឹកឆ្អិន និងចំណីអាហារស្អាត" ។

លោកនិម សុខហាក់ អាយុ ២៧ឆ្នាំ អ្នកជំងឺមកពីភូមិមួយក្នុងស្រុកចំការលើ ខេត្តកំពង់ចាម បាននិយាយឱ្យដឹងថា លោកមានអារម្មណ៍សប្បាយរីករាយណាស់ ព្រោះមណ្ឌលបានផ្តល់ឱ្យលោកនូវការស្នាក់នៅ ចំណីអាហារ ថ្នាំពេទ្យ ព្រមជាមួយនិងការបណ្តុះបណ្តាលខ្លះអំពីរបៀបរស់នៅ...-ល- ។ លោកបានបន្ថែមថា: "ខ្ញុំក៏មានពេលវេលាខ្លះដើម្បីលេងកំសាន្ត ជាមួយអ្នកថែទាំអ្នកជំងឺនានា ដូចជាលេងព្យាណូជាដើម" ។



អ្នកស្រីមិន សារិន អ្នកជំងឺទឹកនោមផ្អែម អាយុ ៥៧ឆ្នាំ ដែលមានស្រុកកំណើតនៅស្រុកឈូក ខេត្តកំពត បានមានប្រសាសន៍ឱ្យដឹងថា ក្រៅពីការជួយរបស់ព្រះសហគមន៍ អ្នកស្រីក៏កត់សម្គាល់ឃើញថាគ្រីស្តបរិស័ទកាតូលិក គឺយកចិត្តទុកដាក់ចំពោះគ្នាទៅវិញទៅមក និងមានសាមគ្គីភាព ។ អ្នកស្រីបានបន្ថែមថា : "ខ្ញុំធ្លាប់បានបាត់បង់ក្តីសង្ឃឹមពីព្រោះខ្ញុំគ្មានលុយដើម្បីទទួលការព្យាបាល ។ ប៉ុន្តែអ្វីៗ បានល្អប្រសើរហើយនៅពេលឥឡូវនេះ" ។

លោកបូជាចារ្យប៉្រុយណូ កូសមី ទទួលខុសត្រូវប្រចាំព្រះសហគមន៍កាតូលិកសន្តយ៉ូសែប បានមានប្រសាសន៍ឱ្យដឹងថាកន្លងមកព្រះសហគមន៍ គិតគូរដល់អ្នកជំងឺ ដែលជាជនក្រីក្រ និងងាយរងគ្រោះ ។ លោកបន្តថា : "សកម្មភាពនៅក្នុងមណ្ឌល គឺដូចជាយើងចង់លើកទឹកចិត្តពួកគាត់ក្នុងការរស់នៅ និងចង់បង្ហាញសក្ខីភាពនៃសេចក្តីស្រឡាញ់ពីព្រះជាម្ចាស់ ដោយមិនប្រកាន់សាសនា" ។



Photo : P. Samphy

**ខាន់ ភិរម្យ**

## កម្ពុជា-ថៃ រៀបចំពិព័រណ៍ពាណិជ្ជកម្មរួមគ្នា

ពិព័រណ៍ពាណិជ្ជកម្មកម្ពុជា-ថៃ មានរយៈពេល៤ថ្ងៃ បានសម្ពោធនៅមជ្ឈមណ្ឌលកោះពេជ្រ ក្រោមអធិបតីភាពរបស់ឧបនាយករដ្ឋមន្ត្រីថៃ និងឯកឧត្តមចម ប្រសិទ្ធ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មកម្ពុជា។

លោកត្រៃរ៉ុង សុវណ្ណគីរី ឧបនាយករដ្ឋមន្ត្រីថៃ មានប្រសាសន៍ថា ទំនាស់ព្រំដែនមិនធ្វើឱ្យប៉ះពាល់ទំនាក់ទំនងពាណិជ្ជកម្មប្រទេសទាំងពីរឡើយ។

លោកបានឱ្យដឹងថា ទំនាក់ទំនងពាណិជ្ជកម្មរវាងប្រទេសទាំងពីរកើនឡើង ៥៤% ឬកើនពី ១,៦ពាន់លានដុល្លារ នៅក្នុងឆ្នាំ២០០៩ ទៅដល់២,៥ ពាន់លានដុល្លារ នៅក្នុង ឆ្នាំ២០១០។

ពិព័រណ៍ពាណិជ្ជកម្មនេះត្រូវបានរៀបចំពីថ្ងៃទី១៧ ដល់ថ្ងៃទី២០ ខែកុម្ភៈ ដោយមានការដាក់តាំងពិព័រណ៍ស្តង់ទំនិញ ថៃចំនួន ១៥៣ស្តង់ និងកម្ពុជាចំនួន ២៥ស្តង់។ ពិព័រណ៍នេះទាក់ទាញអ្នកចូលទស្សនាប្រមាណ ១០០០០នាក់ ក្នុងមួយថ្ងៃ។

## កម្ពុជា និងថៃយល់ព្រមទទួលអ្នកសង្កេតការណ៍ឥណ្ឌូនេស៊ី

ទំនាស់ព្រំដែនកម្ពុជា-ថៃ លើផ្ទៃដីទំហំ ៤,៦គម២ ដែលបានឈានដល់ការប្រយុទ្ធគ្នាដោយអាវុធ និងធ្វើឱ្យបាត់បង់ជីវិតទាំងសងខាង បានឈានដល់កិច្ចព្រមព្រៀងទទួលយកអ្នកសង្កេតការណ៍ឥណ្ឌូនេស៊ី។

លោកម៉ាទី ណាតាឡេហ្គាវ៉ា រដ្ឋមន្ត្រីការបរទេសឥណ្ឌូនេស៊ី អះអាងនៅក្រោយជំនួបរវាងឯកឧត្តមហោ ណាំហុង រដ្ឋមន្ត្រីការបរទេសកម្ពុជា និងឯកឧត្តមកាស៊ិត ភិរម្យ រដ្ឋមន្ត្រីការបរទេសថៃថា ឥណ្ឌូនេស៊ី នឹងបញ្ជូនក្រុម អ្នកសង្កេតការណ៍ជាជនស៊ីវិល និងយោធា មកត្រួតពិនិត្យមើលការឈប់បាញ់ ដែលភាគីទាំងពីរបានយល់ព្រម។

ឯកឧត្តមហោ ណាំហុង មានប្រសាសន៍ថា ឥណ្ឌូនេស៊ី នឹងបញ្ជូនអ្នកអង្កេតការណ៍១៥នាក់ មកកម្ពុជា និង១៥នាក់ ទៅថៃ។ ឯកឧត្តមបន្តថា នេះគឺជាជោគជ័យមួយរបស់ប្រទេសកម្ពុជា និងជាលទ្ធផលនៃការប្តឹងរបស់កម្ពុជា ទៅកាន់ក្រុមប្រឹក្សាសន្តិសុខសហប្រជាជាតិ។

នៅមុនពេលកិច្ចចរចាកម្ពុជា បានប្រកាសទាមទារ ៤ចំណុច ទាក់ទងនឹងបញ្ហាទំនាស់ព្រំដែនជាមួយនិងប្រទេសថៃ រួមមាន៖ ទីមួយ ភាគីទាំងពីរត្រូវចុះហត្ថលេខាលើកិច្ចព្រមព្រៀងឈប់បាញ់មួយដោយមានអាស៊ានជាសាក្សី។ កម្ពុជា និងថៃត្រូវរក្សាទីតាំងឈរជើងកងទ័ពរបស់ខ្លួនឱ្យនៅមួយកន្លែង និងហាមចល័តកម្លាំង។ ភាគីទាំងពីរត្រូវលើកទឹកចិត្តឱ្យមេទ័ពជួរមុខជួបគ្នាដើម្បីបន្ធូរបន្ថយភាពតានតឹង ហើយចុងក្រោយ ភាគីទាំងពីរត្រូវទទួលយកអ្នកសង្កេតការណ៍អាស៊ានឱ្យមកពិនិត្យមើលបទឈប់បាញ់ជាអចិន្ត្រៃយ៍មួយ។

កាលពីថ្ងៃទី១៦ ខែកុម្ភៈ កន្លងទៅនេះ សភាសហភាពអឺរ៉ុបក៏បានធ្វើការអំពាវនាវឱ្យប្រទេសទាំងពីរបញ្ឈប់អរិភាពនឹងគ្នា ដោយកម្លាំងប្រដាប់អាវុធ ហើយគោរពនូវសាលក្រមតុលាការអន្តរជាតិទីក្រុងឡាអេ ឆ្នាំ១៩៦២ ដែលសម្រេចឱ្យកម្ពុជាឈ្នះក្តី និងគោរពអនុសញ្ញាទីក្រុងឡាអេ ស្តីអំពីកិច្ចគាំពារទ្រព្យសម្បត្តិវប្បធម៌ដែលជាបេតិកភណ្ឌនៃមនុស្សជាតិ។

## អង្គការសុខភាពពិភពលោក៖ ស្រាសម្លាប់ជីវិតមនុស្សច្រើនជាងជំងឺ និងអំពើហិង្សា

បើយោងតាមអង្គការសុខភាពពិភពលោក ដែលបានអះអាងជាផ្លូវការកាលពីពាក់កណ្តាលខែកុម្ភៈកន្លងទៅនេះ បានឱ្យដឹងថា នៅទូទាំងពិភពលោក គ្រឿងស្រវឹងបង្កឱ្យមនុស្សស្លាប់ប្រមាណជា ៤% នៅក្នុងចំណោមមូលហេតុដែលបណ្តាលឱ្យស្លាប់មនុស្ស។

ប្រភពដដែលនោះក៏អះអាងឱ្យដឹងទៀតដែរថា តួលេខនៃការស្លាប់ដោយសារគ្រឿងស្រវឹងច្រើនជាងជំងឺអេដស៍ ជំងឺរបេង និងជំងឺហិង្សាផ្សេងៗ ទៅទៀតផង។

"គ្រឿងស្រវឹងក្រៅពីជាមូលហេតុ ដែលបណ្តាលឱ្យមានអត្រាស្លាប់ខ្ពស់ហើយនោះ វាក៏ជាបញ្ហាមួយដែលរាំងដល់ការអភិវឌ្ឍន៍ដែរ"។ នេះបើតាមសេចក្តីប្រកាសរបស់អង្គការសុខភាពពិភពលោក។

ប្រភពពីអង្គការសុខភាពពិភពលោកដដែល បានអះអាងថា ទូទាំងពិភពលោកនេះ មាន មនុស្សប្រមាណ ២,៥ លាននាក់ ដែលមានអាយុប្រមាណពី១៥ ទៅ ៥៩ឆ្នាំ បានស្លាប់បាត់បង់ជីវិតដោយសារមូលហេតុផ្សេងៗ ដែលពាក់ព័ន្ធនឹងគ្រឿងស្រវឹង។

ប្រភពដដែលនោះ អះអាងទៀតថា ការផឹកស៊ីច្រើនហួសប្រមាណជាបញ្ហាជំងឺចម្បងមួយនៅលើពិភពលោក ជាពិសេសនៅឯទ្វីបអាស៊ី និងអាហ្វ្រិក ដែលជាទ្វីបពីរមានប្រជាពលរដ្ឋរស់នៅច្រើនជាងគេ។

## គ្រោះរញ្ជួយដីញូវសេឡែន សម្លាប់មនុស្ស ៧៥នាក់ និងបាត់ខ្លួនជាង ៣០០នាក់

គ្រោះរញ្ជួយដីដែលបានកើតមានឡើងនៅក្នុងទីក្រុងធំទីពីររបស់ប្រទេសញូវសេឡែន កាលពីចុងខែកុម្ភៈ កន្លងទៅនេះ បានបណ្តាលឱ្យបាត់បង់ជីវិតមនុស្សយ៉ាងហោចណាស់ជាង ១០០នាក់ និងមនុស្សចំនួន ៣០០នាក់ កំពុងបាត់ខ្លួន។

វិទ្យុអូស្ត្រាលី បានអះអាងថា គ្រោះរញ្ជួយដីនេះបានកើតមានឡើងនៅក្នុងទីក្រុងគ្រីស្ទឆឺច ដែលជាទីក្រុងធំទីពីររបស់ប្រទេសញូវសេឡែន។ រលករញ្ជួយដែលមានកម្រិត ៦,៣ រិចទ័រ បានបណ្តាលឱ្យអគារធំៗ ផ្ទះ និងហេដ្ឋារចនាសម្ព័ន្ធជាច្រើនត្រូវរងនូវការខូចខាត។

កាសែតវ៉ាស៊ីនតោនប៉ុស្តិ៍ បានរាយការណ៍ដែរថា ដើម្បីជួយដល់ប្រទេសញូវសេឡែន រដ្ឋាភិបាលអាមេរិកបានបញ្ជូនក្រុមអ្នកសង្គ្រោះដើម្បីទៅធ្វើការរួមគ្នាជាមួយនឹងក្រុមសង្គ្រោះនៅក្នុងប្រទេសញូវសេឡែន។ គ្រោះរញ្ជួយដីបានវាយប្រហារទៅលើទីក្រុងនេះផ្ទួនៗ ក្រោយពេលមានការរញ្ជួយបានកើតមានឡើងម្តង កាលពីខែកញ្ញា ឆ្នាំ២០១០ មុននេះ។



Photo : DR

**ខាន់ ភិរម្យ**

# មាសបៃតងគឺជាគោលដៅថ្មីសម្រាប់សេដ្ឋកិច្ចកម្ពុជា

**ខាន់ ភីរម្យ**

*វិស័យទេសចរណ៍ នៅក្នុងប្រទេសកម្ពុជា ត្រូវបានគេដឹងថា ជាសសរស្តម្ភមួយដ៏សំខាន់សម្រាប់គាំទ្រកំណើនសេដ្ឋកិច្ច ហើយថ្មីៗនេះរដ្ឋាភិបាលនៃប្រទេសកម្ពុជាបានប្រកាសប្រែក្លាយវិស័យនេះឱ្យទៅជាមាសបៃតង។ តើមាសបៃតងមានអត្ថន័យយ៉ាងដូចម្តេច ? អ្នកនាំសារសូមណែនាំមិត្តអ្នកអានឱ្យជួបជាមួយនិងលោកសេង ទៀក នាយកអង្គការមូលនិធិសត្វព្រៃពិភពលោក ។*

**អ្នកនាំសារ: តើលោកយល់យ៉ាងណាចំពោះគម្រោងដែលកម្ពុជាកំពុងប្រែក្លាយវិស័យទេសចរណ៍ឱ្យទៅជាមាសបៃតង ?**

**លោកសេង ទៀក :** អង្គការមូលនិធិសត្វព្រៃពិភពលោកសូមស្វាគមន៍ និងគាំទ្រគម្រោង ដែលកម្ពុជាកំពុងតែប្រែក្លាយខ្លួន ឱ្យទៅជាប្រទេសមួយ ដែលយកវិស័យទេសចរណ៍ ឱ្យទៅជាមាសបៃតង ដែលនឹងអាចរួមចំណែកកាត់បន្ថយនូវភាពក្រីក្ររបស់ប្រជាជននៅមូលដ្ឋាន និងលើកកម្ពស់នូវសេដ្ឋកិច្ចជាតិ នាខណៈពេលដែលកម្ពុជាមានសក្តានុពលខ្ពស់លើធម្មជាតិ ដោយសារខ្លួនរក្សាបាននូវបណ្តុំតំបន់ព្រៃទេសភាពសំខាន់ៗ និងសត្វព្រៃកម្រៗជាច្រើនប្រភេទ ដែលមានតម្លៃខ្ពស់ជាសកល ។



Photo : WWF

លោកសេង ទៀក កំពុងបង្ហាញអតីតឯកអគ្គរដ្ឋអាមេរិកអំពីគម្រោងផ្ទះលំហែដែលភ្ញៀវទេសចរណ៍កំពុងពេញនិយម

**អ្នកនាំសារ : តើមកដល់ពេលបច្ចុប្បន្ននេះ អង្គការមូលនិធិសត្វព្រៃពិភពលោកកំពុងតែធ្វើអ្វីការងារលើគម្រោងនេះ?**

**លោកសេង ទៀក**: អង្គការបានកំពុងសហការយ៉ាងជិតស្និទ្ធជាមួយរាជរដ្ឋាភិបាលកម្ពុជា ក្នុងការលើកទឹកចិត្តសហគមន៍ និងអាជ្ញាធរមូលដ្ឋាន ឱ្យចូលរួមក្នុងការការពារធនធានព្រៃឈើ និងសត្វព្រៃតាមការទាញយកប្រយោជន៍ពីការអនុវត្តគម្រោង និងសកម្មភាពទេសចរណ៍បែបធម្មជាតិមួយចំនួនដែលកំពុងដំណើរការនៅក្នុងតំបន់ព្រៃស្រោង ភាគខាងកើតក្នុងខេត្តមណ្ឌលគិរី ។

**អ្នកនាំសារ : តើអង្គការមូលនិធិសត្វព្រៃបានធ្វើអ្វីខ្លះហើយនៅក្នុងគម្រោងនេះ ?**

**លោកសេង ទៀក:** យើងកំពុងគាំទ្រដល់ការអនុវត្តគម្រោងផ្ទះលំហែសហគមន៍ដើម្បីចូលរួមវិភាគទានលើកកម្ពស់ចំណូលរបស់សហគមន៍ និងលើកទឹកចិត្តឱ្យការអភិរក្សធនធានធម្មជាតិនៅក្រៅនិងក្នុងតំបន់ការពារ ។ គម្រោងផ្ទះលំហែសហគមន៍បានចាប់ផ្តើមនៅឆ្នាំ២០០៩ ហើយស្ថិតក្រោមការគ្រប់គ្រងផ្ទាល់ដោយក្រុមសហគមន៍ទេសចរណ៍ធម្មជាតិ ដែលមានសមាជិកសុទ្ធសឹងតែជាជនជាតិដើមភាគតិចព្នងចំនួន ១៣គ្រួសារ ។ លើសពីនេះអង្គការដាប់ប៊ីយូដាប់ប៊ីយូអេហ្វ (WWF) និងរដ្ឋបាលព្រៃឈើក៏គ្រោងនឹងដាក់ឱ្យដំណើរការនូវគម្រោងផ្ទះលំហែ លំដាប់ទំនើបនៅតាមបណ្តោយដងទន្លេស្រែពកក្នុងពេលឆាប់ៗនេះដែរ ។

**អ្នកនាំសារ : តើការប្រែក្លាយវិស័យទេសចរណ៍ឱ្យទៅជាមាសបៃតងនេះនឹងផ្តល់ផលប្រយោជន៍យ៉ាងណាទៅដល់សហគមន៍ ?**

**លោកសេង ទៀក :** ផលប្រយោជន៍ទី១ គឺសមាជិកសហគមន៍ទទួលបានប្រាក់ចំណូលបន្ថែមតាមរយៈការផ្តល់ជាសេវាកម្មទេសចរណ៍ ។ទី២ពួកគាត់បានទទួលចំណេះ ស្តីអំពីសត្វព្រៃ និងជីវចម្រុះនៅក្នុងតំបន់ និងជំនាញថ្មីៗបន្ថែមពាក់ព័ន្ធនឹងការងារគ្រប់គ្រងសេវាកម្មទេសចរណ៍ បដិសណ្ឋារកិច្ច មគ្គុទេសក៍ទេសចរណ៍... និង ទី៣ ពួកគាត់មានឱកាសចូលរួមដោយផ្ទាល់ក្នុងការថែរក្សាការពារធនធានព្រៃឈើ និងសត្វព្រៃក្នុងតំបន់ពួកគាត់ ។



Photo : Merril Halley

ទិដ្ឋភាពដងទន្លេស្រែពកនៅខេត្តរតនគីរី ដែលមានធម្មជាតិស្រស់ត្រកាលដែលសមស្របសម្រាប់សាងសង់ផ្ទះលំហែ និងបង្កើតរមនីយដ្ឋានទទួលភ្ញៀវទេសចរណ៍ ជាច្រើនដែលមានចំណង់ចំណូលចិត្តធ្វើការស្រាវជ្រាវ និងកំសាន្តជាមួយនិងធម្មជាតិ

## បញ្ហាប្រឈមរបស់កម្ពុជាសម្រាប់ការងារមាសបៃតង

លោកសេង ទៀក បានអះអាងថា ការប្រែក្លាយវិស័យទេសចរណ៍ឱ្យទៅជាមាសបៃតង គឺយើងគួរតែផ្តោតការយកចិត្តទុកដាក់លើបញ្ហាប្រឈមមួយចំនួនដូចជាការធានានូវនិរន្តរភាពថវិកា ការកសាង និងការពង្រឹងសមត្ថភាពដល់មន្ត្រីមានសមត្ថកិច្ចសម្រាប់ការងារអភិរក្ស ការកំណត់ឱ្យបានច្បាស់លាស់នូវផែនការប្រើប្រាស់ដីធ្លី ជាពិសេសដីព្រៃសម្រាប់អភិរក្ស ការទប់ស្កាត់ ការបរបាញ់ និងការធ្វើពាណិជ្ជកម្មសត្វព្រៃខុសច្បាប់ ការទប់ស្កាត់ការជួញឈើខុសច្បាប់ ព្រមទាំងអភិរក្សនូវវប្បធម៌ និងប្រពៃណីរបស់ជនជាតិដើមភាគតិចផងដែរ។

## បទយកការណ៍

# ទីផ្សារអង្ករ និងបញ្ហាប្រឈមរបស់កម្ពុជាដើម្បីក្លាយជ

**ខាន់ ភីរម្យ**

អ្នកសេដ្ឋកិច្ចកម្ពុជាបានអះអាងថា ស្រូវអង្ករជាឱកាសនិងធនធានដ៏ប្រសើរ សម្រាប់គាំទ្រកំណើនសេដ្ឋកិច្ចរបស់ប្រទេស។ ប៉ុន្តែការប្រែក្លាយកម្ពុជាឱ្យទៅជាអ្នកនាំចេញអង្ករដ៏ចម្បងមួយ គឺជាបញ្ហាប្រឈមនៅឡើយនាបច្ចុប្បន្ននេះ។

កម្ពុជាមានគម្រោងប្រែក្លាយឱ្យទៅជាប្រទេសនាំចេញអង្ករមួយដ៏ចម្បង ត្រឹមឆ្នាំ២០១៥ ជាមួយនិងបរិមាណនាំចេញប្រមាណជា ១លានតោន ។

ប៉ុន្តែលោកឃិន ពិសី អ្នកស្រាវជ្រាវនៅវិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា បានគូសបញ្ជាក់ថា កម្ពុជានៅមានបញ្ហាប្រឈមជាច្រើន ដើម្បីបំពេញទៅតាមផែនការដែលខ្លួនកំណត់។ លោកប្រាប់ថា គម្រោងនាំចេញអង្ករឱ្យបាន១លានតោននៅក្នុងឆ្នាំ២០១៥ មានបញ្ហាប្រឈម បើទោះជាផលិតផលស្រូវរបស់ប្រទេសនៅសល់ប្រមាណជា ៣លានតោនក្នុងមួយឆ្នាំៗក៏ដោយ។ ផលិតផលស្រូវដែលកសិករផលិតបានហើយនោះ តែងហូរចេញដោយផ្ទាល់ទៅកាន់ប្រទេសជិតខាងដូចជាថៃ និងវៀតណាម ដែលនេះជាមូលហេតុចម្បងមួយអាចធ្វើឱ្យប៉ះពាល់ទៅដល់និរន្តរភាពនៃការផ្គត់ផ្គង់ជាស្រូវ ឱ្យទៅបណ្តារោងម៉ាស៊ីនកិនស្រូវទាំងនៅក្នុងប្រទេស និងទៅទីផ្សារក្រៅប្រទេស។

តាមការសិក្សាស្រាវជ្រាវរបស់លោកឃិន ពិសី បច្ចុប្បន្ននេះ ទីផ្សារអង្កររបស់កម្ពុជាធំជាងគេ គឺសហភាពអឺរ៉ុប ដែលនៅទីនោះអង្ករកម្ពុជា កំពុងទទួលបានការគាំទ្រ ដោយសារគុណភាពល្អ ហើយតម្លៃវិញក៏ប្រសើរជាងបណ្តាលប្រទេសនាំចេញផ្សេងៗ ជាពិសេសគឺប្រទេសថៃ និងវៀតណាម។ លោកបានឱ្យដឹងថា អង្ករកម្ពុជានៅលើទីផ្សារនៅអឺរ៉ុប គឺមានតម្លៃថោកជាងអង្ករថៃនិងវៀតណាមប្រមាណជា១៥០ដុល្លារ។ប៉ុន្តែអង្ករកម្ពុជាអាចនឹងបាត់បង់លទ្ធភាពប្រកួតប្រជែង នៅពេលដែលសហភាពអឺរ៉ុបលែងអនុគ្រោះពន្ធនាំចូល។ លោកបានឱ្យដឹងថាការចំណាយទៅលើសង្វាក់ផលិតកម្មស្រូវដើម្បីក្លាយជាអង្ករនាំចេញនោះ គឺវាមានតម្លៃខ្ពស់ជាងថៃ និងវៀតណាមជាខ្លាំង។ លោកបញ្ជាក់ថា: "ប្រសិនបើយើងនាំចេញអង្ករទៅកាន់ទីផ្សារហុងកុងនោះអង្ករកម្ពុជាថ្លៃជាងថៃ៧៤ដុល្លារហើយថ្លៃជាងវៀត-ណាម ៧៦ដុល្លារក្នុងមួយតោន។ តែបើនៅទីផ្សារអឺរ៉ុបវិញ ដោយសារតែគេអនុគ្រោះពន្ធយើងថោកជាងថៃ ១៥៤ ដុល្លារ ហើយវៀតណាមវិញនោះ គឺថោកជាងចំនួន ១៥១ ដុល្លារ"។

លោកសុខ ហាច នាយកនៃក្រុមហ៊ុនហ្គោលដិនរ៉ាយ ដែលគឺជាក្រុមហ៊ុននាំចេញអង្ករមួយដ៏ចម្បងមួយនោះ បានអះអាងថា ទីផ្សារធំរបស់ក្រុមហ៊ុនលោកក្នុងពេលនេះ គឺនៅឯសហភាពអឺរ៉ុប។ ប៉ុន្តែលោកកំពុងតែព្រួយបារម្ភដែរ ដោយសារការអនុគ្រោះពន្ធនាំចូលអង្ករពីកម្ពុជានឹងត្រូវផុតកំណត់ក្នុងរង្វង់ឆ្នាំក្រោយនេះ។ លោកបញ្ជាក់ប្រាប់ឱ្យដឹងថា: "បើអត់មានទីផ្សារអនុគ្រោះពន្ធក្នុងការនាំចូលទេ ការប្រកួតប្រជែងរបស់កម្ពុជា គឺផុយស្រួយណាស់ បើប្រៀបធៀបជាមួយថៃ និងវៀតណាម។ ដូច្នេះរដ្ឋាភិបាលកម្ពុជាគួរតែចាត់វិធានការ"។

នៅក្នុងខណៈពេលដែលអ្នកសេដ្ឋកិច្ច ហើយនិង




### ក្រុមហ៊ុន ២០០រួមគ្នា បង្កើតសមាគមនាំចេញអង្ករមួយ

នៅក្នុងកិច្ចប្រឹងប្រែងមួយដើម្បីជំរុញឱ្យកម្ពុជាក្លាយទៅជាប្រទេសនាំចេញអង្ករមួយទៅកាន់ទីផ្សារអន្តរជាតិ នៅក្នុងឆ្នាំ ២០១៥ខាងមុខនេះ ក្រុមហ៊ុននៅក្នុងស្រុកប្រមាណជា ២០០បាន រួមគ្នាបង្កើតសមាគមនាំចេញអង្ករមួយ។

បើតាមប្រសាសន៍របស់លោកលឹម ប៊ុនហេង ប្រធានសមាគមស្បៀង និងនាំចេញអង្ករទៅកាន់ទីផ្សារអន្តរជាតិ បានឱ្យដឹងថា សមាគមរបស់លោកបានបង្កើតឡើងកាលពីថ្ងៃទី១២ ខែកុម្ភៈកន្លងទៅដើម្បីគាំទ្ររដ្ឋាភិបាលកម្ពុជា លើផែនការនៃការនាំចេញអង្ករទៅកាន់ទីផ្សារអន្តរជាតិ។

លោកលឹម ប៊ុនហេង បានឱ្យដឹងទៀតថា ក្រៅពីអង្ករ ក្រុមហ៊ុនរបស់លោកក៏មានផែនការជំរុញការនាំចេញផលិតផលកសិកម្មផ្សេងៗទៀត ដូចជាពោត សណ្តែក...-ល-។

# ាយជាអ្នកនាំចេញអង្ករដ៏សំខាន់




Photo : S. Philong

អ្នកនាំចេញស្រូវនិយាយពីបញ្ហាប្រឈមនានានោះ កសិករនៅតាមតំបន់ជនបទកំពុងតែស្រែកថ្ងូរ នៅខណៈពេលដែលផលស្រូវធ្វើបានច្រើនហើយ។ តែតម្លៃនៃការលក់ចេញ គឺមិនត្រឹមតែមិនចំណេញទេ ថែមទាំងត្រូវជំពាក់គេទៀត។

អ្នកស្រីណង់ចម្រើន ជាកសិករនៅស្រុកបាកាន ខេត្តពោធិ៍សាត់ បានអះអាងថា ឆ្នាំនេះ គាត់គួរតែរីករាយដោយសារតែផលស្រូវរបស់គាត់បានច្រើនជាងឆ្នាំទៅ។ ជាមួយនិងដីស្រែចំនួនជាង ៥ហិចតា នៅឆ្នាំនេះគាត់ប្រមូលផលស្រូវប្រមាណ ១៥តោន លើសពីឆ្នាំទៅប្រមាណជា៣តោន។ ប៉ុន្តែពេលនេះ គាត់បានត្រឹមតែស្រក់ទឹកភ្នែកចំពោះបំណុលគេអំពីលើរឿងទិញជីនិងថ្លៃប្រេងចាក់គោយន្ត។ តែតម្លៃស្រូវបែរជាថោកពេក។

បើតាមការអះអាងរបស់ អ្នកស្រីណង់ ចម្រើន តម្លៃស្រូវមិនត្រឹមតែថោកទេ សឹងតែគ្មានទីផ្សារទៅទៀតឆ្នាំនេះ។ កាលឆ្នាំមុន ក្រៅពីរោងម៉ាស៊ីនកិនស្រូវក្នុងស្រុកចុះមកដណ្ដើមគ្នាទិញស្រូវ ឈ្មួញថៃ និងវៀតណាម ក៏ចុះមកទិញ ដល់ស្រុកបាកានដែរ។ តែពេលនេះដូចជាស្ងាត់តែម្ដង។ អ្នកស្រីបានបញ្ជាក់ ថា: "ថោកអីចឹងហើយ! ខ្ញុំដឹកទៅលក់ឱ្យគេដល់រោងម៉ាស៊ីន គេថា អត់យកទៀតដោយសារស្រូវគេសល់ច្រើន អត់កន្លែងដាក់"។

លោកស៊ិន សុខហេង កសិករនៅស្រុកថ្មគោល ខេត្តបាត់ដំបង បានឱ្យដឹងថា ពីឆ្នាំមុន ស្រូវក្រអូបច្រូតហើយ យើងលក់បានទាំងសើម ១តោនជាង ១0000បាត ឆ្នាំនេះបានត្រឹម ៦000 ទៅ៧000បាតប៉ុណ្ណោះ ហើយឈ្មួញសាញច្រើនទៀត។ ខ្ញុំមិនដឹងថា ហេតុអ្វីបានជាវាថោកនោះទេ។ ប៉ុន្តែខ្លះគេថាមកពីស្រូវវាជន់ពេក។

ជុំវិញបញ្ហានេះលោក សុខ ហាច បានឱ្យដឹងថា កសិករសូមកុំភ័យស្រូវអង្ករនេះ មិនអត់ទីផ្សារទេ សូមកុំអាលលក់ ឥឡូវស្តុកទុកសិន យ៉ាងយូរខែ៣ ឬខែ៤នេះ តម្លៃស្រូវនឹងឡើងវិញហើយ។ លោកបញ្ជាក់ថា: "នាពេលនេះស្បៀងនៅលើពិភពលោកមានតម្លៃណាស់។ឥឡូវស្រូវជន់ខ្លាំងបែបនេះ គឺវាធ្លាក់តម្លៃហើយ"។

ស្តុកជាដំណោះស្រាយមួយ។ ប៉ុន្តែកសិករភាគច្រើនបានអះអាងថា ប្រសិនបើគេរក្សាទុក តើមានអ្វីកើតឡើង? ចំពោះបំណុលរបស់ពួកគេ ដែលការប្រាក់កើនឡើងជារៀងរាល់ខែនោះ។

អ្នកស្រីណង់ ចម្រើន បានបញ្ជាក់ថា : "ឱ្យស្តុកយ៉ាងម៉េចនឹងកើត? បើដាច់ខែមិនទាន់គេមកទារការប្រាក់ និងការបង់រំលោះ"។

ក្រសួងកសិកម្មបានឱ្យដឹងថា នៅក្នុងចំណោមតួលេខនេះកម្ពុជារក្សាទុកប្រមាណជា ១,0៣លានតោនសម្រាប់ធ្វើជាពូជ ២,0១លានតោន សម្រាប់បំពេញសេចក្ដីត្រូវការក្នុងស្រុក។ ដូច្នេះកម្ពុជាត្រូវគេរំពឹងទុកថា មានប្រមាណជា ៣,៧លានតោន ឬមួយស្មើនឹង ២,៤លានតោនអង្ករសម្រាប់ធ្វើការនាំចេញ។ ប៉ុន្តែដើម្បីជំរុញការនាំចេញនេះកម្ពុជាត្រូវការប្រាក់ដល់ទៅរាប់លានដុល្លារដើម្បីប្រមូលទិញសម្រាប់បម្រើការនាំចេញ ។

មន្ត្រីនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មួយរូបបានអះអាងថា កម្ពុជាត្រូវការថវិកា រហូតដល់ទៅ ៣៥0លានដុល្លារ ដើម្បីប្រមូលទិញផលិតផលស្រូវទាំងអស់។ ប្រភពដដែលនេះក៏បានឱ្យដឹងថា ដើម្បីជំរុញការនាំចេញអង្ករកម្ពុជាទៅដល់ទីផ្សារអន្តរ-ជាតិ រដ្ឋាភិបាលកម្ពុជាក៏បានសម្រេចផ្ដល់ប្រាក់កម្ចីប្រមាណ៣៦លានដុល្លារ ឱ្យសមាគមសម្ព័ន្ធម៉ាស៊ីនកិនស្រូវកម្ពុជា ដើម្បីប្រមូលទិញស្រូវ ខណៈដែលសមាគមសម្ព័ន្ធម៉ាស៊ីនកិនស្រូវកម្ពុជា បានឱ្យដឹងថាខ្លួនមានទុនសរុបត្រឹម១៣៦លានដុល្លារប៉ុណ្ណោះ ដើម្បីធ្វើការប្រមូលទិញស្រូវ។

សមាគមសម្ព័ន្ធម៉ាស៊ីនកិនស្រូវកម្ពុជា ឱ្យដឹងថា រហូតដល់ពេលនេះ ខ្លួនមានទុនផ្ទាល់ចំនួនប្រមាណ ៧៥លានដុល្លារ។ កម្ចីពីរដ្ឋាភិបាលមានចំនួន ៣៦លានដុល្លារ ហើយ២៥លានដុល្លារទៀត គឺបានមកពីកម្ចីធនាគារពាណិជ្ជនៅក្នុងប្រទេស។

ចំនួនទុនសរុបរបស់បណ្ដារោងម៉ាស៊ីនកិន ស្រូវនៅប្រទេសកម្ពុជា មានចំនួនតិចតួចនៅឡើយ នាខណៈដែលនៅវៀតណាម និងថៃ គឺមានទំហំច្រើនជាងនេះឆ្ងាយណាស់។ វៀតណាមជាប្រទេសមួយគេដឹងថា គឺជាប្រទេសនាំចេញអង្ករលេខ២ ត្រៀមទុនប្រមាណ ១២ពាន់លានដុល្លារ ហើយថៃដែលជាប្រទេសនាំចេញ លំដាប់លេខ១វិញ គឺមានត្រៀមបម្រុងថវិកាដល់ ៤ពាន់លានដុល្លារ ដើម្បីធ្វើការប្រមូលទិញស្រូវបម្រើការនាំចេញរបស់ពួកគេ។

## អ្នកសេដ្ឋកិច្ចជំរុញការបង្កើតធនាគារស្រូវ

លោកឃិន ពិសី អ្នកស្រាវជ្រាវនៃវិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា បានអះអាងថា ធនាគារស្រូវគួរតែជាដំណោះស្រាយបញ្ហាប្រឈមរបស់កសិករ និងអាចគាំទ្រផែនការនាំចេញស្រូវរបស់កម្ពុជា។

លោកឃិន ពិសី បានអះអាងទៀតថា ផលិតផលស្រូវរបស់កម្ពុជាត្រូវបានផលិតលើស។ ប៉ុន្តែទាំងកសិករ រោងម៉ាស៊ីន ព្រមទាំងរដ្ឋាភិបាល នៅប្រឈមមុខទៅនឹងបញ្ហាសំខាន់មួយ គឺទុន និងឃ្លាំង។ ដូច្នេះការបង្កើតធនាគារស្រូវគួរតែជាមធ្យោបាយមួយដែលអាចឆ្លើយតបទៅនឹងបញ្ហានេះបាន។ លោកបានបញ្ជាក់ថា: "ខ្ញុំគិតថា ធនាគារស្រូវជាផ្លូវមួយដើម្បីប្រែក្លាយកម្ពុជាឱ្យទៅជាប្រទេសនាំចេញអង្ករមួយនៅមុន ឆ្នាំ ២0១៥"។ លោកបន្តទៀតថា រដ្ឋាភិបាលកម្ពុជា ស្ថាប័នមីក្រូហិរញ្ញវត្ថុ និងធនាគារនានា ព្រមទាំងរោងម៉ាស៊ីនកិនស្រូវគួរតែធ្វើការជាមួយគ្នាដើម្បីបង្កើតការគ្រប់គ្រង និងជំរុញគំនិតនេះឱ្យលេចចេញជារូបរាងបាន។

# យើងជាគ្រីស្តបរិស័ទមានតម្លៃនៅក្នុងសង្គម

**អ៊ុម  សុខន**




ការិយាល័យយុវជនកាតូលិក ភូមិភាគភ្នំពេញ រៀបចំនូវសិក្ខាសាលាលើកទីពីរនៅព្រះសហគមន៍កាតូលិកកំពត ខេត្តកំពត ចាប់ពីថ្ងៃទី១៩-២០ ខែកុម្ភៈមុននេះ ។ សិក្ខាសាលាត្រូវបានគេរៀបចំឡើងដោយរិះគិត និងពិភាក្សាស្តីអំពីប្រធានបទ "យើងជាគ្រីស្តបរិស័ទមានតម្លៃក្នុងសង្គម"នៅក្រោមការណែនាំ និងសម្របសម្រួលដោយលោកផុន សុផល និងលោកបូជាចារ្យកូស្តារ៉ូ ។ អង្គសិក្ខាសាលានេះគឺមានយុវជនចូលរួមប្រមាណពី៧០-៨០នាក់ ។

លោកផុនសុផល ជាអ្នកសម្របសម្រួលកម្មវិធីនេះបានឱ្យដឹងថា សិក្ខាសាលានេះលើកឡើងស្តីអំពីយើងជាគ្រីស្តបរិស័ទ ដែលមានតម្លៃក្នុងសង្គមនេះ ដោយផ្តោតសំខាន់ទៅលើចំនុចរួមបី : ទីមួយ ការបង្រៀនខ្លួនឱ្យក្លាយទៅជាប្រជាពលរដ្ឋល្អ នៅក្នុងសង្គម ដែលមានន័យថា ការសិក្សាស្វែងយល់ និងចេះបែងចែកអ្វីខុស និងអ្វីត្រូវ? ។ ទីពីរ ឥទ្ធិពលល្អរបស់គ្រីស្តបរិស័ទក្នុងសង្គម មានខ្លឹមសារថា ទង្វើគប្បី ឬយ៉ាងណា? គឺវាស្តែងតាមរយៈការរស់នៅប្រចាំថ្ងៃរបស់យើងដែលមានបងប្អូននៅជុំវិញ និងសកម្មភាពដែលខ្លួនធ្វើដាក់ខ្លួនឯង ហើយចំនុចទីបីគួសបញ្ជាក់ អំពីការតភ្ជាប់ជីវិត ក្នុងព្រះសហគមន៍ និងសង្គម គឺការរស់នៅ ។

លោកផុន សុផល ក៏បានបន្តទៀតដែរថា គោលបំណងនៃការរៀបចំសិក្ខាសាលានេះ គឺជាទិសដៅដែលដើរស្រប និងកម្មវិធីអប់រំ របស់ការិយាល័យយុវជន ដែលបាននឹងកំពុងធ្វើ សម្រាប់ឆ្នាំ២០១១ ដើម្បីឆ្ពោះទៅរកចំណេះដឹងនៅក្នុងសង្គម ។

# រៀបចំឱ្យយុវជនស្គាល់អំពី "ព្រះបន្ទូល" នាំឱ្យយល់អំពីការត្រាស់ហៅ

ក្រុមអេម៉ាណូអែល បានរៀបចំនូវសិក្ខាសាលាមួយស្តីអំពី "ព្រះបន្ទូល" ដែលមានយុវជនចូលរួមស្វែងយល់ចំនួន ៧នាក់ និងអ្នកណែនាំចំនួន ៤នាក់ផ្សេងទៀត នៅសាលាដុនបូស្កូទឹកថ្លា នៅរាជធានីភ្នំពេញ កាលពីថ្ងៃទី ៥-៦ ខែកុម្ភៈកន្លងទៅនេះ ។

លោកបូជាចារ្យអ៊ុន សុន ជាអ្នកទទួលខុសត្រូវនៃក្រុមអេម៉ាណូអែល ក៏បានមានប្រសាសន៍ឱ្យដឹងថា: "អ្វីដែលក្រុមរៀបចំ គឺចង់ឱ្យយុវជនបានស្វែងយល់ថា តើអ្វីទៅ គឺជាការត្រាស់ហៅ? និងគោលបំណងរបស់ខ្លួនពួកគេទៅថ្ងៃអនាគត" ។

លោកបូជាចារ្យអ៊ុន សុន បានបន្តដែរថា សិក្ខា-សាលានេះ ត្រូវបែងចែកឡើងជា២ដំណាក់កាល: ទី១គេរិះគិតអំពីថា "តើព្រះបន្ទូលជាអ្វី? តើអ្វីទៅជាព្រះគម្ពីរ? និង ការផ្តល់សក្ខីភាពអំពីព្រះបន្ទូលក្នុងដំណើរជីវិតប្រចាំថ្ងៃ" ។ ហើយសម្រាប់ដំណាក់កាលទី២ គឺគេផ្តោត លើការអធិដ្ឋាន និងស្មឹងស្មាធិ៍អំពីប្រធានបទ "អ្នកសាបព្រោះស្រូវ" ។

លោកបូជាចារ្យរូបនេះ បន្ថែមថា វាពិតជាមានសារៈសំខាន់ណាស់ សម្រាប់យើង ជាគ្រីស្តបរិស័ទដែលត្រូវយល់ដឹងអំពីផ្លូវរបស់ខ្លួនដែលមានជាការត្រាស់ហៅ ផ្សេងៗគ្នា និងការចូលស្វែងយល់ អំពីជីវិតនៃការត្រាស់ហៅក្នុងក្រុមអេម៉ាណូអែល ។

នេះគឺជារបៀបម្យ៉ាងដែលអាចជួយនាំយើងឱ្យស្គាល់ និងយល់អំពីសេចក្តីពិតនៃការត្រាស់ហៅ ។

លោកអ៊ុន សុន បានបន្ថែមឱ្យដឹងទៀតថា តាមធម្មតា សម្រាប់អ្នកចង់ស្វែងយល់អំពីជីវិត នៃការត្រាស់ហៅ គេចាំបាច់ត្រូវតែចូលរួមក្នុងសកម្មភាពក្រុមអេម៉ាណូអែល ដែលតែងមានធ្វើការប្រជុំ ៦ដងក្នុង១ឆ្នាំ ។ ហើយប្រសិនបើអ្នកដែលចូលស្វែងយល់អំពីដំណាក់កាល ដំបូងនេះ ចង់បន្តទៅជំហានទី២ ដែលមានឈ្មោះថាដំណឹងល្អនោះ គេត្រូវតែចូលរួមការប្រជុំរាល់មួយខែម្តង ។ បន្ទាប់មក ទើបគេអាចសរសេរពាក្យ សុំចូលសិក្សាស្វែងយល់ នៅទេវវិទ្យាល័យដែលជាកន្លែងអប់រំយុវជនកាតូលិកឱ្យក្លាយជាបូជាចារ្យបាន ។

**សុខន**

## ក្រុមសន្តវ៉ាំងសង់ ដឺប៉ូល យកចិត្តទុកដាក់អំពីបញ្ហាសុខភាពប្រជាពលរដ្ឋ

បង្គន់អនាម័យចំនួន ១២ ត្រូវផ្តល់ជូនដល់ក្រុមគ្រួសារដែលរស់ក្នុងភូមិចំនួន៤ នៅឃុំអំពិល ស្រុកកំពង់សៀម ខេត្តកំពង់ចាម កាលពីដើមខែកុម្ភៈឆ្នាំ២០១១ កន្លងទៅ។

ភូមិចំនួន៤ ដែលទទួលបានបង្គន់អនាម័យនោះរួមមាន ភូមិអណ្តូងច្រោះ ដែលទទួលបាន៣បង្គន់ ភូមិជើងគោក ១បង្គន់ ភូមិក្រោយផ្សារភ្នំ ៤បង្គន់ និងភូមិស្រឡៅ ៤បង្គន់។

បងស្រីឌុច វណ្ណី ប្រធានក្រុមសន្តហ្វ្រង់ស្វ័រ អាស៊ីស៊ីនៃក្រុមសន្តវ៉ាំងសង់ ដឺប៉ូល បានប្រាប់អំពីគោលបំណងនៃការផ្តល់បង្គន់អនាម័យដល់អ្នកភូមិថា: "តាមអ្វីដែលក្រុមរបស់យើងធ្លាប់ចុះសួរសុខទុក្ខប្រជាជនរស់នៅទីនេះឃើញថា កូនៗរបស់ពួកគាត់ច្រើនកើតជំងឺរាគរូស ជាពិសេសលើកុមារ ព្រោះក្រុមគ្រួសាររបស់ពួកគាត់មានជីវភាពខ្វះខាតដែលមិនមានលទ្ធភាពក្នុងការសាងបង្គន់អនាម័យដោយខ្លួនឯង។ ហេតុនេះពួកគាត់ច្រើនតែបត់ជើងនៅតាមទីវាលហើយកូនៗរបស់ពួកគាត់ បន្ទោរបង់នៅតាមរបង ឬបរិវេណផ្ទះ"។

បងស្រីឌុច វណ្ណី បន្តយ៉ាងនេះថា សម្រាប់ការសាងសង់ គឺអ្នកភូមិត្រូវចំណាយខ្លួនឯង។ ប៉ុន្តែចំពោះសម្ភារៈ ដូចជាចានបង្គន់ លូ ៥កង់ សង្ក័សី ៣សន្លឹក គ្របលូ ចំនួន២ ស៊ីម៉ង់ ៥គីឡូក្រាម និងទុយោខ្លះ គឺក្រុមសន្តហ្វ្រង់ស្វ័រ អាស៊ីស៊ី នៃក្រុមសន្តវ៉ាំងសង់ឌឺប៉ូល ជាអ្នកទិញជូនដែលបង្គន់នីមួយៗ និងចំណាយអស់៨០ដុល្លា។

គួរបញ្ជាក់ផងដែរថា ក្រុមសន្តហ្វ្រង់ស្វ័រ អាស៊ីស៊ីតែងធ្វើការចុះសួរសុខទុក្ខបងប្អូននៅតាមភូមិយ៉ាងតិចណាស់ ២ដងក្នុងមួយខែ និងមានកម្មវិធីអប់រំសុខភាពអនាម័យដល់អ្នកភូមិផងដែរ។

**សុខន**

## យុវជនកាតូលិកតៃវ៉ាន់ ១៦នាក់ ជួសជុលផ្ទះដល់អ្នកភូមិ

**អ៊ឹម សុខន**

យុវជនកាតូលិកតៃវ៉ាន់ ១៦នាក់ បានជួយជួសជុលផ្ទះឱ្យដល់អ្នកភូមិខ្វះខាតចំនួនពីរគ្រួសារដែលរស់នៅភូមិតាអំ ឃុំប្រាសាទ ស្រុកព្រះនេតព្រះ នាខេត្តបន្ទាយមានជ័យចាប់ពីថ្ងៃទី១១-១៨ ខែកុម្ភៈ ឆ្នាំ២០១១ កន្លងទៅ ។

លោកធីម ធន់ ដែលជាអ្នកទទួលខុសត្រូវព្រះសហគមន៍ ខេត្តសៀមរាប បានមានប្រសាសន៍ឱ្យដឹងថា សកម្មភាពជួសជុលផ្ទះដល់បងប្អូនខ្មែរនេះគឺជាសកម្មភាពនៃក្រុមទីពីររបស់ក្រុមយុវជនតៃវ៉ាន់ដែលពួកគេបានធ្វើកាលពីខែមុន និងកន្លងទៅបាន ២ដងរួចមកហើយ ។

លោកបន្តឱ្យដឹងទៀតថា ប្រការសំខាន់ដែលនាំឱ្យក្រុម យុវជនតៃវ៉ាន់នេះមកជួយជួសជុលផ្ទះដល់ប្រជាពលរដ្ឋ គឺដោយសារតែក្តីស្រលាញ់ ដែលពួកគេមានសម្រាប់បងប្អូនប្រជាជនខ្មែរ ហើយដ្បិតពួកគេយល់ថា យើងគឺជាបងប្អូននឹងគ្នាក្នុងនាមព្រះជាម្ចាស់តែមួយ ។

ការជួសជុលផ្ទះចំនួនពីរខ្នងនេះ នឹងចំណាយទឹកប្រមាណ ៤០០ដុល្លារ ។ យ៉ាងណាមិញ ក្រៅពីការជួសជុលផ្ទះ ក្រុមយុវជនតៃវ៉ាន់នេះមានការរៀបចំនូវកម្មវិធីអាហារជាបបរដើម្បីបំប៉នដល់ក្មេងៗនៅក្នុងភូមិនេះផងដែរ ។

លោកធីម ធន់ បានបន្ថែមថា ក្រុមយុវជនតៃវ៉ាន់ ១៦នាក់នេះ នឹងបន្តការចុះសួរសុខទុក្ខដល់អ្នកភូមិដែលរស់នៅភូមិព្រៃកទាល់ភូមិកំពង់ឃ្លាំង និងភូមិពាក់ស្នែង ខេត្តសៀមរាប ។

## ព្រះសហគមន៍រៀបចំសិក្ខាសាលារបៀបអប់រំកុមារ លើប្រធានបទ "ឱ្យលុយកូន"

សាលាមត្តេយ្យថ្នាំពេជ្ររៀបចំនូវកិច្ចប្រជុំមាតាបិតាស្តីអំពីប្រធានបទ "ឱ្យលុយកូន" កាលពីថ្ងៃទី ១៥ ខែកុម្ភៈ នៅជិតទីក្រុងកំពង់ចាម ដែលកម្មវិធីតែងតែប្រារព្ធធ្វើឡើង រៀងរាល់ពីរខែម្តង នៅលើប្រធានបទផ្សេងៗគ្នា ។

លោកបូជាចារ្យសេរ៉ាលដឺ វ៉ូសាំង ជាអ្នកទទួលខុសត្រូវសាលាមត្តេយ្យថ្នាំពេជ្រ បានមានប្រសាសន៍ឱ្យដឹងអំពីគោលបំណងការរៀបចំកិច្ចប្រជុំនេះថា កត្តាជីវភាពជាអ្នកចំការ និងការទម្លាប់ជាលក្ខណៈឱ្យប្រាក់ទៅកូន ទើបកូនព្រមធ្វើកិច្ចការអ្វីមួយនោះ ដូចជា ឱ្យលុយទើបកូនទៅរៀននោះ ជាទម្លាប់មិនល្អដែលវាអាចបន្តឱ្យក្មេងៗទាំងនេះ យកទៅធ្វើជាគំរូពេលដែល ពួកគេក្លាយជាអាណាព្យាបាលរបស់កូនវិញម្តង ។ ដូច្នេះទើបយើងប្រាប់ពីររបៀបដែលត្រឹមត្រូវក្នុងការអប់រំពួកគេ ។

លោកបូជាចារ្យមានប្រសាសន៍ដែរថា ការយកពាក្យដោះស្រាយថា កូននៅតូចមិនទាន់ដឹងអ្វីនោះ គ្រាន់តែជាទង្វើមួយដែលនឹងអាចនាំឱ្យកូនរបស់ខ្លួនក្លាយជាបុគ្គល មិនចេះរង់ចាំក្នុងការបំពេញកិច្ចការងារអ្វីមួយ? និងកាន់តែមិនយល់អំពីតម្លៃ នៃកម្លាំងពលកម្ម ។ យ៉ាងណាមិញ ក្នុងនាមយើងជាអាណាព្យាបាល គួរណាស់តែយកចិត្តទុកដាក់អប់រំកូនចៅឱ្យយល់ដឹងអំពីតម្លៃនៃកម្លាំងពលកម្ម និងកាលៈទេសៈក្នុងការចាយវាយ ត្បិតការចេះរៀបចំបញ្ហាចំណាយចំនូលនេះ ជារឿងមួយ ដែលអាចនាំសុភមង្គលដល់ក្រុមគ្រួសារផងដែរ ។

**សុខន**

## ហាងកាហ្វេផ្សារភ្ជាប់ទំនាក់ទំនងប្រជាកសិករ

កាលពីថ្ងៃទី២៩ ខែមករា ឆ្នាំ២០១១ កន្លងទៅថ្មីៗនេះ នៅព្រះសហគមន៍កោះរកាក្រៅ មានរៀបចំគម្រោងការថ្មីមួយដើម្បីជួយសម្រួលដល់បងប្អូនក្នុងភូមិឱ្យមានភាពងាយស្រួលក្នុងការប្រាស្រ័យទាក់ទង និងរកបទពិសោធន៍អំពីការងារកសិកម្ម។

ដើម្បីសម្រួលដល់បញ្ហានេះ ព្រះសហគមន៍បានរៀបចំកន្លែងមួយ ដែលមានទីតាំងនៅក្នុងភូមិនេះ គឺហាងលក់កាហ្វេ ដែលមានឈ្មោះថា មិត្តសម្លាញ់ ហើយនៅក្នុងហាងនេះដែរ មានដាក់នូវកាសែត ព័ត៌មាន ទស្សនាវដ្តី កសិកម្មព្រមទាំងបណ្ណាល័យមួយសម្រាប់ឱ្យបងប្អូនអាន និងស្រាវជ្រាវ។

ក្នុងឱកាសនៃការបើកហាងកាហ្វេនេះ មានការអញ្ជើញចូលរួមពីសំណាក់លោកអន់តូនី សាមីស៊ូ សៃរាជ ជាអភិបាលព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាម លោកមេឃុំកោះរកា លោកមេឃុំ កោះទន្ទឹម ព្រមទាំងលោកបូជាចារ្យ លោកមេភូមិ និងគ្រីស្តបរិស័ទ រួមជាមួយប្រជាជនដែលរស់នៅក្នុងភូមិនេះផងដែរ។ ក្នុងកម្មវិធីនេះលោកសេរ៉ាល់ វ៉ូសាំង បូជាចារ្យទទួលបន្ទុកនៅព្រះសហគមន៍ បានមានប្រសាសន៍ថា ហាងកាហ្វេនេះបើកឡើង ដើម្បីជួយសម្រួលដល់បងប្អូន ដែលមានបំណងស្វែងយល់អំពីរបៀបថ្មីៗ ក្នុងការដាំដុះដំណាំកសិកម្ម។

ក្នុងឱកាសនេះដែរ លោកមេឃុំកោះរកាបានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះគម្រោងនៃកម្មវិធី។ លោកក៏បានជំរុញ និងលើកទឹកចិត្តដល់ព្រះសហគមន៍ដែលបានជួយអភិវឌ្ឍន៍សង្គម។ **តាំង ម៉េងឈុន**



Photo : T. Meng Chun

### បន្តជំនឿគឺជាការងាររបស់យើង

នៅរៀងរាល់មួយខែម្តង ព្រះសហគមន៍ការតូលិកភូមិកោះរកាក្រៅ បានរៀបចំកម្មវិធីមួយដើម្បីជួបជាមួយបងប្អូនចំនួន១៥នាក់ដែលស្ម័គ្រជួយបន្តជំនឿដល់អស់បង-ប្អូន ដែលមានបំណងចង់ស្គាល់ព្រះយេស៊ូ ។ ក្នុងការប្រជុំគ្នានេះ បងប្អូនមានគោលបំណងជួយលើកទឹកចិត្តគ្នាទៅវិញទៅមក និងជួយសម្រួលបញ្ហា និងកង្វះខាតផ្សេងៗនៅពេលអប់រំជំនឿបងប្អូនដែលកំពុងស្វែងយល់ ។

កម្មវិធី ក៏ត្រូវបានសម្របសម្រួល ដោយលោកសេរ៉ាល់ ជាបូជាចារ្យណែនាំព្រះសហគមន៍ ។ កម្មវិធីនេះ យើងបានមើលផងដែរអំពីមេរៀន ឬរបៀបនៃការប្រជុំជាមួយបងប្អូន និងមានការផ្លាស់ប្តូរពិសោធន៍ពី គ្នាទៅវិញទៅមកដើម្បីចែករំលែកនូវអ្វីដែលយើងមាន ។ ទាំងអស់នេះជាអំណរសប្បាយដែលយើងទទួលពីព្រះជាម្ចាស់ !

# ព្រះសហគមន៍កាតូលិកតាហែន ស្វែងរកទីផ្សារលក់ផលិតផលទៅបរទេស

**ខាន់ ភីរម្យ**

អាវ ក្រមា កាបូប ផង់យាម ក្រណាត់ទ្រនាប់ចាន ក្រណាត់ទ្រនាប់កែវជាដើម គឺសុទ្ធសឹងតែជារបស់កែច្នៃរបស់បងប្អូន នៃព្រះសហគមន៍តាហែនដែលអាចស្វែងរកទីផ្សារនៅក្រៅប្រទេសបាន។

កញ្ញាឯល ម៉ាស់ ទទួលខុសត្រូវផ្នែកទីផ្សារនៃព្រះសហគមន៍តាហែន បានអះអាងថា ជាមួយនិងសម្ភារៈទាំងអស់នោះ ព្រះសហគមន៍គឺបាននាំចេញទៅកាន់ប្រទេសមួយចំនួនរួចមកហើយមានដូចជាប្រទេស អាឡឺម៉ង់ អេស្ប៉ាញ កូរ៉េខាងត្បូង ឬអូស្ត្រាលីជាដើម។ក្រៅពីនេះ គឺព្រះសហគមន៍អាចលក់ផ្ទាល់នៅក្នុងព្រះសហគមន៍កាតូលិក ឬបម្រើដល់ភ្ញៀវទេសចរណ៍ជាទូទៅដែលបានមកដល់ព្រះសហគមន៍តាហែន។

កញ្ញាបានបន្តទៀតថាកាលពីឆ្នាំ២០១០ ទីផ្សារធំរបស់យើង គឺប្រទេសអាល្លឺម៉ង់ ដោយបានបញ្ជាទិញផលិតផល ពីព្រះសហគមន៍តាហែន ប្រមាណជា១៥ម៉ឺនសម្រាប់ដោយមានតម្លៃលក់រាយមួយៗគឺ២៥០០រៀល។ ប្រទេសអេស្ប៉ាញបានបញ្ជាទិញពីយើងប្រមាណពី៣០០ ទៅ៥០០អាវ ជាមួយនិងតម្លៃនៃការលក់ចេញ ក្នុងអាវមួយ មានតម្លៃ ១២ ដុល្លារ។ ក្រៅពីនេះទៀត យើងអាចលក់ចេញបានខ្លះនៅកាន់កូរ៉េខាងត្បូង និងប្រទេសអូស្ត្រាលី នៅពេលដែលយើងបានត្រូវគេអញ្ជើញទៅសម្តែងនៅក្នុងប្រទេសទាំងនោះ។

កញ្ញាបានបញ្ជាក់ទៀតថា : ‟ឆ្នាំនេះយើងបើកទីផ្សាររបស់យើងបានច្រើនខណៈដែលឆ្នាំទៅយើងនាំចេញតែទៅអេស្ប៉ាញតែប៉ុណ្ណោះ”។

អ្នកស្រីម៉ិញ ម៉ិច ជាអ្នកសម្របសម្រួលមណ្ឌលវប្បធម៌ប្រពៃណី ភ្លេង និងសិប្បកម្មនៃព្រះសហគមន៍តាហែនបានមានប្រសាសន៍ឱ្យដឹងថាគម្រោងនេះ មានដើមកំណើតដំបូង គឺចេញមកពីការបណ្តុះបណ្តាលវិជ្ជាជីវៈខាងកាត់ដេរ ប្រមាណពី ៣ទៅ ៤ ឆ្នាំមុន ដែលព្រះសហគមន៍កាតូលិកផ្តល់ដល់សហគមន៍មូលដ្ឋានប្រជាជន។ នៅបច្ចុប្បន្នគម្រោងនេះកំពុងផ្តល់ផលប្រយោជន៍ឱ្យដល់សហគមន៍បានមួយចំនួនផងដែរ។

អ្នកស្រីបានបញ្ជាក់ដែរថា : ‟មកដល់ពេលនេះយើងពង្រីកពី៥ម៉ាស៊ីន នៅក្នុងព្រះសហគមន៍ ទៅដល់៨០ម៉ាស៊ីន នៅទូទាំងព្រះសហគមន៍ ហើយបើយើងមានទីផ្សារកាន់តែធំ។យើងរំពឹងថាយើងនឹងពង្រីកវាបន្តទៅទៀត”។

អ្នកស្រីបានឱ្យដឹងទៀតផងដែរថា ក្រៅពីរបស់របរខាងលើនេះដែរព្រះសហគមន៍តាហែនអាចនឹងមានសមត្ថភាពទទួលធ្វើនូវរបស់សិប្បកម្មផ្សេងៗទៅតាមការបញ្ជាទិញពីខាងក្រៅផងដែរ។អ្នកស្រីបានបន្តទៀតថា មកដល់សព្វថ្ងៃនេះ វត្ថុធាតុដើមទាំងអស់គឺបានពីទីផ្សារ គឺលើកលែងតែក្រមាមួយចេញ ដែលយើងបានតម្បាញ និងធ្វើការកាត់ដេរនៅក្នុងព្រះសហគមន៍កាតូលិកផ្ទាល់ ។

អ្នកស្រីបន្ថែមទៀតថា នៅក្នុងពេលសព្វថ្ងៃនេះសិប្បកម្មនៅតាហែន បានចាប់ផ្តើមទាក់ទាញភ្ញៀវទេសចរណ៍បរទេស និងលក់វត្ថុអនុស្សាវរីយ៍ផ្សេងៗបានមួយចំនួនផងដែរ។

អ្នកស្រីបញ្ជាក់ថា : ‟របស់ដែលយើងលក់មានតម្លៃចាប់ពី២៥០០រៀល រហូតដល់១២ដុល្លារ”។



Photo : Bishop Kike

# "ត្រឹមតែ២ ឬ៣នាក់ព្រះអង្គគង់ជាមួយ"

**អ៊ឹម សុខន**



Photo : F. Totet

ប៉ុល ខាំថង ជាឈ្មោះស្ត្រីវ័យ ៥២ឆ្នាំម្នាក់ ដែលនិយាយថា៖ "ព្រះជាម្ចាស់ទ្រង់បានត្រាស់ហៅបុត្រធីតារបស់ព្រះអង្គឱ្យដើរតាមផ្លូវសុចរិត។ សម្រាប់ខ្ញុំជាអ្នកបម្រើរបស់ព្រះអង្គក៏ដូច្នោះដែរ"។

នៅខែសីហា ឆ្នាំ១៩៧៩ គឺជាពេលវេលាមួយដែលរូបអ្នកស្រី និងគ្រួសារ ត្រូវគេជន្លៀស ឱ្យទៅនៅជំរំសាយធូនាប្រទេសថៃ បន្ទាប់ពីរបបប៉ុលប៉តត្រូវបានបញ្ចប់។ ការរស់នៅជាជនភៀសខ្លួន គឺជារឿងមួយមិនងាយស្រួលនោះឡើយនៅពេលដែលប្រទេសឆ្លងដំណាក់កាលសង្គ្រាមមួយ"។ អ្នកស្រីក៏និយាយថា៖ "ការរស់នៅគឺខ្វះមុខខ្វះក្រោយ"។

អ្នកស្រីមានប្រសាសន៍បន្ថែមថា៖ "អ្នកនៅផ្ទះក្បែរខ្ញុំប្រាប់ថា ឱ្យតែចូលសាសនា យើងចាំតែយកប្រាក់។ នេះជាហេតុដំបូង ខ្ញុំចូលព្រះសហគមន៍ គឺដើម្បីក្រពះនៅឆ្នាំ១៩៨៧"។ អ្នកស្រីបន្តថា បន្ទាប់មកអ្នកស្រីបានស្តាប់អត្ថបទមួយ និយាយថា "តើអ្នកមករកអ្វី?" ពេលនោះអ្នកស្រីចាប់ផ្តើមរិះគិតពីទង្វើ និងចិត្តរបស់ខ្លួនថា ហេតុអ្វីចូលស្វែងយល់ពីព្រះសហគមន៍? អ្នកស្រីនិយាយថា៖ "ដំបូងគេមិនឱ្យខ្ញុំរៀនអត្ថបទគម្ពីរអ្វីទេគេថា គឺមានតែគ្រូអប់រំជំនឿ និងគ្រីស្តបរិស័ទទើបរៀនបាន។ ខ្ញុំសួរលោកអភិបាលអ៊ីវរ៉ាមូសពីរឿងនេះ។ លោកក៏ប្រាប់ថា៖ "ព្រះគម្ពីរគឺសម្រាប់មនុស្សទាំងអស់គ្នា"។ អ្នកស្រីនិយាយទៀតថា ក្រោយមក គេមិនឱ្យខ្ញុំជ្រមុជទឹកនៅពេលនោះ ខ្ញុំយំខ្លាំងណាស់ តែមិនដឹងហេតុអ្វី? រហូតដល់ឆ្នាំ១៩៨៩ ទើបខ្ញុំទទួលពិធីជ្រមុជទឹក។ ខ្ញុំក៏យល់ថា នេះជាអ្វីដែលព្រះជាម្ចាស់ចង់ឱ្យខ្ញុំបន្តស្វែងយល់អំពីចិត្តខ្លួនឯងឱ្យបានច្បាស់"។

ដល់ឆ្នាំ១៩៩២ ទើបក្រុមគ្រួសាររបស់អ្នកស្រីប៉ុល ខាំថង មករស់នៅឯភូមិតាពូង ស្រុកថ្មគោល ខេត្តបាត់ដំបង។ អ្នកស្រីនិយាយថា៖ "ពេលនោះខ្ញុំជិះម៉ូតូឌុបមកអធិដ្ឋាននៅបាត់ដំបងរាល់អាទិត្យជាមួយកូនមិនដែលខានទេ។ មានម្តងនោះលោកអភិបាលប្រាប់ថា បើធ្វើដូច្នេះ ខ្ញុំត្រូវចំណាយប្រាក់ច្រើន។ លោកប្រាប់ខ្ញុំថា គួរប្រមូលគ្រីស្តបរិស័ទឯទៀតមកជួបជុំគ្នា នៅទីនេះ (ភូមិតាពូង) "គឺមានគ្នាត្រឹមតែ២ ឬ៣នាក់ ព្រះអង្គគង់ជាមួយ"។

សព្វថ្ងៃអ្នកស្រីប៉ុល ខាំថង បានបម្រើការងារនៅព្រះសហគមន៍ប៉ៃលិន ធ្វើជាគ្រូអប់រំជំនឿ និងអ្នកទទួលខុសត្រូវនូវកិច្ចការផ្សេងៗ។ អ្នកស្រីនិយាយដោយចិត្តសង្ឃឹមថា៖ "អ្វីដែលអ្នកស្រីធ្វើ គឺព្រះជាម្ចាស់ជាអ្នកចាត់មក។ ហេតុនេះខ្ញុំរំពឹងថា យុវជនជាគ្រីស្តបរិស័ទជំនាន់ក្រោយ គឺរឹតតែមានជំនឿរឹងមាំ និងពឹងផ្អែកជីវិតរបស់ខ្លួនលើព្រះជាម្ចាស់។

## ថ្វាយអភិបូជាសម្រាប់វិញ្ញាណក្ខន្ធបងស្រីអ៊ីរាំង វីជីនៀ Irang Virginia

ព្រះវិហារសន្តយ៉ូសែប (ព្រះសហគមន៍ផ្សារតូច) នៅរាជធានីភ្នំពេញ នឹងរៀបចំថ្វាយអភិបូជាសម្រាប់វិញ្ញាណក្ខន្ធរបស់បងស្រីអ៊ីរាំង វីជីនៀ នៅថ្ងៃទី២៤ កុម្ភៈ វេលាម៉ោង ៦:១៥នាទីល្ងាច ដែលមានលោកអភិបាលអូលីវីយេ ស្មឺតអឺស្លែ ជាអធិបតីភាព។

អស់រយៈកាលជិត ១០ឆ្នាំ ដែលបងស្រីអ៊ីរាំង វីជីនៀ មានបេសសកម្មនៅក្នុងប្រទេសកម្ពុជា។ បងស្រីបានចូលមកប្រទេសកម្ពុជានៅឆ្នាំ២០០១។

កិច្ចការងាររបស់បងស្រីគឺមើលថែទាំអ្នកជំងឺនៅមណ្ឌលទទួលអ្នកជំងឺព្រះវិហារសន្តយ៉ូសែប (ព្រះសហគមន៍ផ្សារតូច) ក្នុងឆ្នាំ២០០១-២០០៦។ ក្នុងឆ្នាំ២០០៦-២០០៨ បងស្រីត្រូវបានជ្រើសតាំងជាបងស្រីប្រធាននៅខេត្តបាត់ដំបង។ ពីឆ្នាំ២០០៩-២០១០ បងស្រីជាអ្នកទទួលខុសត្រូវនៅមន្ទីរពេទ្យព្រះកុមារយេស៊ូស្ថិតនៅក្នុងមន្ទីរពេទ្យបង្អែកជូនកែវក្នុងខេត្តតាកែវ។

នៅក្នុងខែឧសភា ឆ្នាំ២០១០ បងស្រីបានចាកចេញពីប្រទេសកម្ពុជាទៅប្រទេសហ្វីលីពីនដើម្បីសម្រាកព្យាបាលជំងឺ។ បងស្រីកើតនៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៤៩ ជាជនជាតិហ្វីលីពីន និងជាសមាជិកនៃក្រុមគ្រួសារ បុត្រីនៃ មេត្តាករុណា (Daughter of Charity) បានទទួលមរណភាពកាលពីថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១១ វេលាម៉ោង៣ និង៤០នាទីរសៀល ក្នុងជន្មាយុ ៦១ឆ្នាំ នៅប្រទេសហ្វីលីពីន ដោយជំងឺមហារីកសួត។

**ទត តឹមស្មៀន**



Photo : Daugters of Charity

# ព្រះសហគមន៍កាតូលិកកម្ពុជាសោកស្តាយចំពោះការប្រយុទ្ធនៅព្រំដែន

**ជាត សំភី**



Photos : Cambodian Caritas

នៅក្នុងសេចក្តីថ្លែងការណ៍ចុះថ្ងៃទី១៤ ខែកុម្ភៈ និងចុះហត្ថលេខា ដោយលោកអភិបាលសុខកុមារ អូលីវីយេ ជ្មឹតអីស្លែរ នៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ ព្រះសហគមន៍កម្ពុជាបានសម្តែងនូវការសោកស្តាយយ៉ាងខ្លាំងចំពោះការប្រយុទ្ធប្រដាប់អាវុធកាលដើមខែកុម្ភៈកន្លងទៅ នៅតំបន់ប្រាសាទព្រះវិហារ ។

សេចក្តីថ្លែងការណ៍បានអធិប្បាយថា : "ព្រះសហគមន៍សូមរួមចំណែកក្នុងទុក្ខលំបាកនេះដែលជាទុក្ខលំបាករួមរបស់ជាតិយើងទាំងមូល និងរបស់មនុស្សជាតិ ។

យោងតាមសេចក្តីថ្លែងការណ៍ ព្រះសហគមន៍កាតូលិកកម្ពុជាសូមអំពាវនាវដល់គ្រប់អង្គការសហគមន៍ជាតិ និងអន្តរជាតិទាំងអស់សូមចូលរួមចំណែកតាមសមត្ថកិច្ចគ្រប់រូបភាព ដើម្បីបញ្ឈប់ជាបន្ទាន់នូវការប្រយុទ្ធដោយប្រដាប់អាវុធនៅតំបន់ប្រាសាទព្រះវិហារ ពីព្រោះជម្លោះនេះ បានបណ្តាលឱ្យបាត់បង់នូវអាយុជីវិតដ៏មានតម្លៃរបស់មនុស្ស បណ្តាលឱ្យប្រជាជនរងទុក្ខលំបាក ជាខ្លាំង និងដែលបានបំផ្លាញនូវទីសក្ការៈរបស់ប្រជាជន និងប្រាង្គប្រាសាទដែលជាបេតិកភណ្ឌដ៏មានតម្លៃរបស់មនុស្សជាតិនេះផង ។

លោកឡុង សុផល អ្នកសម្របសម្រួលកម្មវិធីអភិវឌ្ឍន៍របស់អង្គការជេអេស៊ី នៅខេត្តកណ្តាល បានមានប្រសាសន៍ថា លោកគាំទ្រទាំងស្រុងចំពោះលោកអភិបាល និងបំណងរបស់លោក តាមរយៈសេចក្តីថ្លែងការណ៍ ។ នេះបង្ហាញថា ព្រះសហគមន៍កាតូលិកកម្ពុជាស្អប់សង្គ្រាម និងប្រាថ្នានូវសន្តិភាពជានិរន្តរ៍ ។ លោកបន្ថែមថា : "យើងប្រឆាំងនឹងសង្គ្រាមពីព្រោះ វាផ្តល់ការឈឺចាប់ដល់គ្រប់ៗ គ្នា និងរាំងស្ទះដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ច" ។

លោកដួង សារង្ស ជានាយកមណ្ឌលអប់រំជំនឿព្រះសហគមន៍កាតូលិកកម្ពុជា មានប្រសាសន៍ថា សេចក្តីថ្លែងការណ៍នេះ បានបង្ហាញអំពីការយកចិត្តដាក់របស់ព្រះសហគមន៍ចំពោះមនុស្សគ្រប់ៗរូប ។ នេះធ្វើឱ្យយើងពិចារណាថា សង្គ្រាមមិនគ្រាន់តែនាំមកនូវការឈឺចាប់ចំពោះប្រជាជនកម្ពុជាតែនាំមកនូវការឈឺចាប់សម្រាប់ប្រជាជនទាំងសងខាង ។ លោកបន្ថែមថា : "យើងមិនចង់បានសង្គ្រាមតទៅទៀតទេ ពីព្រោះវានឹងបង្កឱ្យមានគ្រោះថ្នាក់ ភាពក្រីក្រ និងជនភៀសសឹក ។ ហើយវាក៏ធ្វើឱ្យប្រជាជន ទាំងសងខាង លំបាកទំនាក់ទំនងរកទទួលទានជាមួយគ្នាដើម្បីលើកកម្ពស់កម្រិតជីវភាពរបស់ពួកគេផងដែរ" ។

ការប្រយុទ្ធនៅព្រំដែនកម្ពុជាថៃតំបន់ប្រាសាទព្រះវិហារពីថ្ងៃទី៤-៧ កុម្ភៈកន្លងទៅនេះ បណ្តាលឱ្យមនុស្សរាប់សិបនាក់ស្លាប់ និងរបួស( ទាហាន និងជនស៊ីវិល) និងមានជនភៀសសឹករាប់ពាន់គ្រួសារនៅប្រទេសទាំងពីរ ។

## អង្គការការីតាស និងអង្គការមនុស្សធម៌នានាកាត់បន្ថយការលំបាករបស់ជនភៀសសឹក

ជនភៀសសឹកពីការប្រយុទ្ធប្រដាប់អាវុធក្នុងទំនាស់ទ្រទ្រង់ធំរវាងកងទ័ពកម្ពុជា និងថៃ នៅឯព្រំដែនព្រះវិហារចំនួន២០០០គ្រួសារ បានទទួលអំណោយពីអង្គការមនុស្សធម៌មួយចំនួន ដូចជាអង្គការការីតាសកម្ពុជា កាកបាទក្រហមកម្ពុជា និងអង្គការអុកស្វាម។

ប្រជាជនប្រមាណជា ១០០០០នាក់ អាចទទួលនូវកញ្ចប់អំណោយដែលរួមមានអង្ករ ២៥គីឡូក្រាម មុងមួយ ភួយមួយ ក្រមាមួយ និងខោអាវពីរសម្រាប់។ ពួកគាត់ក៏អាចទទួលបាននូវស៊ីទែនទឹកសម្រាប់ផ្គត់ផ្គង់ជំរំប្រមូលផ្តុំចំនួន ៦ នៅក្នុងពីរស្រុក គឺស្រុកជាំក្សាន្ត និងស្រុកគូលែន នៅក្នុងខេត្តព្រះវិហារ។

កម្មវិធីប្រគល់អំណោយមួយត្រូវបានធ្វើឡើងកាលពីថ្ងៃអង្គារ ទី៨ ខែកុម្ភៈ នៅក្នុងភូមិមួយ ក្នុងស្រុកគូលែន ខេត្តព្រះវិហារ ដែលមានចម្ងាយប្រមាណ៧០ គីឡូម៉ែត្រពីតំបន់ប្រយុទ្ធដោយកងទ័ព។

កញ្ញាធួន រតនា បុគ្គលិកផ្នែកសង្គ្រោះគ្រោះមហន្តរាយនៃអង្គការការីតាសកម្ពុជា បានឱ្យដឹងថា ជនរងគ្រោះភាគច្រើន ជាជនក្រីក្រ និងជាកសិករ។ អ្នកខ្លះគឺជាសាច់ញាតិរបស់ទាហាន។ នៅពេលប្រយុទ្ធគ្នាដោយអាវុធ ពួកគាត់ភៀសខ្លួនយ៉ាងរហ័សដោយមិនបានពាំនាំអ្វីមកជាមួយ។ ពួកគាត់មកជ្រកនៅតាមសាលារៀន វត្តអារាម ឬក្រោមម្លប់ឈើ។ ចំណែកអ្នកខ្លះទៀតសុំប្រជាជនក្នុងតំបន់ដើម្បីស្នាក់នៅ។

កញ្ញាធួន រតនា និយាយថា : "បញ្ហាសំខាន់នៅជំរំ គឺការខ្វះខាតនូវអនាម័យ និងថែទាំសុខភាព។ ដូច្នេះជនភៀសសឹករស់នៅយ៉ាងលំបាក"។ កញ្ញាបន្តថា : "ប្រសិនបើស្ថានការណ៍នៅតែបន្ត ប្រជាជនកាន់តែលំបាក"។

អ្នកស្រីឈយ យ៉ុង ជនភៀសសឹកម្នាក់និយាយថា តាំងពីថ្ងៃទី៤ កុម្ភៈ គាត់បានចាកចេញពីលំនៅដែលជាកន្លែងប្រយុទ្ធគ្នាដោយមិនបានរៀបចំខ្លួនអ្វីទេដោយសារមានការផ្ទោងកាំភ្លើងធំច្រើនពេក។ ឥឡូវនេះ គាត់មានការខ្វះខាតសព្វបែបយ៉ាង។ គាត់បន្តថា : "ខ្ញុំព្រួយបារម្ភណាស់។ ខ្ញុំមិនដឹងអំពីសុវត្ថិភាពរបស់ប្តីខ្ញុំដែលជាទាហាននៅសមរភូមិមុខ។ ខ្ញុំក៏លំបាកស្វែងរកចំណីអាហារសម្រាប់កូនៗខ្ញុំផងដែរ"។ គាត់បន្តទៀតថា : "អង្គការនានាផ្តល់អំណោយដល់យើង។ ប៉ុន្តែមិនដឹងថាតើស្ថានភាពនឹងបន្តដល់ពេលណា?"។

លោកគីម រតនា នាយកប្រតិបត្តិនៃអង្គការការីតាសកម្ពុជា មានប្រសាសន៍ថា : "យើងផ្តល់ឱ្យគាត់នូវអំណោយ ជាពិសេសតម្រូវការមូលដ្ឋានដោយសារយើងចង់កាត់បន្ថយការឈឺចាប់របស់ពួកគាត់"។





Photo : N. Nithy

# អ្នកជំនាញអក្សរសាស្ត្រ "ពាក្យដំណាល មានកូនស្រី ដូចមាន ពាងប្រហុកដាក់មុខផ្ទះ" គឺហួសសម័យ

**ខាន់ ភីរម្យ**

លោកបណ្ឌិតស៊ុំឈុំប៊ុន អគ្គលេខាធិការនៃរាជបណ្ឌិតសភាកម្ពុជា មានប្រសាសន៍ថា ពាក្យដំណាលថា "មានកូនស្រី ដូចមានពាងប្រហុកដាក់នៅមុខផ្ទះ" ជាពាក្យដែលហួសសម័យហើយ ដោយសារសម័យនេះគឺជាសម័យ ដែលកម្ពុជាកំពុងអនុវត្ត សមភាពយេនឌ័រ ។

លោកបណ្ឌិតបានមានប្រសាសន៍ដែរថា ពាក្យដំណាលនេះ គឺជាពាក្យដែលគេតាក់តែងមកនៅក្នុងបរិបទសង្គមមនុស្ស មួយចំនួន កាលពីសម័យមុន ហើយវាមានខ្លឹមសារប្រហាក់ប្រហែលគ្នានឹងពាក្យដំណាលមួយចំនួនទៀតដែលគេតែងតែពោលលេងដូចជា "ស្ត្រីបង្វិលចង្ក្រានមិនជុំ" ឬ "ស្រីដូចជាផ្កាស្រស់និងមានក្លិនតែមួយភ្លែត ខណៈដែលបុរសជាមាសទឹក១០ ទោះបីធ្លាក់នៅក្នុងភក់ ក៏លាងទឹកជ្រះ" ។ ទោះបីជាយ៉ាងណា សម័យបច្ចុប្បន្ននេះ ពាក្យស្លោកទាំងអស់នេះហាក់ដូចជាមិនត្រូវទេ ក្នុងបរិបទសង្គមកម្ពុជា នាពេលបច្ចុប្បន្ននេះ ។

តាមប្រសាសន៍របស់លោកបណ្ឌិត ស៊ុំ ឈុំប៊ុន ពាក្យដំណាលនេះច្រើន គឺមានន័យជាអវិជ្ជមាន សំដៅទៅលើស្ត្រី ។ ហើយគេប្រដូចស្ត្រីបានទៅនឹងប្រហុក ដែលមានខ្លិនស្អុយ ឆាប់ធំក្លិន ហើយងាយនឹងទទួលរងនូវការរិះគន់អំពីអ្នកដទៃ និងអ្នកជិតខាងទាំងពួង ដោយសារតែក្បួន ច្បាប់ប្រពៃណី និងទំនៀមទម្លាប់ ។ ប៉ុន្តែនាសម័យបច្ចុប្បន្ន តួនាទីរបស់ស្ត្រី នៅក្នុងសង្គម និងនៅក្នុងការងារទូទៅ គឺត្រូវបានគេលើកតម្កើង ជាបន្តបន្ទាប់ ។

លោកបណ្ឌិតបានបញ្ជាក់ថា: "ស្ត្រីឥឡូវនេះ គឺមិនមែនមិនអាចបង្វិលចង្ក្រានមិនជុំនោះទេ ។ ប៉ុន្តែគេហ៊ានទៅដល់អះអាងស្ត្រីឥឡូវនេះអាចបង្វិលដល់ផែនដីផង" ។

លោកក៏បានបន្តទៀតថា មកដល់ពេលបច្ចុប្បន្ននេះ ទាំងនៅក្នុងគ្រួសារ ឬការងារផ្សេងៗ ក្នុងសង្គមដូចជាអាជីវកម្ម ការងាររាជការ និងអង្គការក្រៅរដ្ឋាភិបាលជាដើម ការងាររបស់ស្ត្រី សុទ្ធតែត្រូវបានគេទទួលស្គាល់ ហើយមានស្ត្រីកម្ពុជាជាច្រើន ដែលទទួលជោគជ័យនៅក្នុងគ្រួសារ និងការងាររបស់ពួកគេនៅក្នុងសង្គម ។

លោកបានបញ្ជាក់ទៀតដែរថា : "មានកូនស្រី ដូចមានពាងប្រហុកដាក់មុខផ្ទះអត់ត្រូវទេ គួរឈប់ប្រើទៅ វាលែងមានតម្លៃហើយពាក្យនេះ" ។

## ពរ ៤ប្រការ របស់អានូ




នេះគឺជារឿងរបស់កុមារាម្នាក់ឈ្មោះអានូ និងទេពធីតា ផ្កាំងដី ។ អានូមិនសប្បាយចិត្តដោយឪពុកម្តាយគេ មានសមាជិកថ្មីម្នាក់ទៀត គឺប្អូនស្រីរបស់គេដែលទើបកើត ។

អ្វីៗផ្លាស់ប្តូរទាំងអស់នៅក្នុងផ្ទះ: ពីមុនឪពុកម្តាយធ្លាប់ស្រលាញ់ និងថ្នាក់ថ្នមអានូរាល់ថ្ងៃ ។ ឥឡូវអានូធ្វើកិច្ចការគ្រប់បែបយ៉ាង គឺស្ទើរគ្មានពេលទំនេរទៅលេងជាមួយមិត្តភក្តិដទៃទៀតក្នុងភូមិ ។ ថ្ងៃមួយ ជាសំណាងល្អ អានូជួបជាមួយទេពធីតា ម៉ាប់ម្នាក់ ឱ្យពរ៤ប្រការឱ្យគេ ។

តើអានូសុំពរអ្វីខ្លះពីទេពធីតា? តើអានូនឹងទៅជាយ៉ាងណានៅពេលដែលបំណងរបស់គេបានសម្រេចហើយ?

សៀវភៅរឿងត្រូវតាក់តែងឡើង និងរំលេចដោយរូបភាពដ៏ស្រស់ស្អាត នឹងជួយប្អូនៗ ឱ្យរៀនអានអក្សរដោយខ្លួនឯង និងយល់ដឹងរឿងរ៉ាវអប់រំមួយចំនួនទៀត ។ រឿងនេះនិពន្ធ និងរចនារូបភាពដោយលោកទ្រី សម្ផស្ស មាន ៤០ទំព័រ មានតម្លៃ២.៥ដុល្លារ និងបោះពុម្ពដោយរោងពុម្ពកូមិកអាត (Comics Art) ។

## ជនរងគ្រោះ




នេះគឺជាប្រលោមលោកខ្នាតខ្លីជាបែបស៊ើបអង្កេតមួយ នៅក្នុងសៀវភៅរឿងបិសាចក្នុងដួងចិត្ត ។ រឿងនេះមានលក្ខណៈអាថ៌កំបាំង និងលាយឡំនឹងចម្ងល់ជាច្រើន ។

ចំណោទរឿងដែលចងបន្តិចម្តងៗ បានទាញនូវចក្ខុអ្នកអានឱ្យបើកនូវសន្លឹកសៀវភៅ ពីទំព័រមួយ ទៅទំព័រមួយទៀតដោយមិនដឹងខ្លួន ។

រាត្រីមួយពេលដែលអេលីស ធមសុន កំពុងតែអង្គុយមើលទូរទស្សន៍តែម្នាក់ឯង ស្រាប់តែមានអធិការប៉ូលីស ២នាក់ចូលទៅចាប់ខ្លួនគាត់ ។ គាត់ក៏ត្រូវគេចោទថា បានសម្លាប់នារីម្នាក់ឈ្មោះហៃឡែន ។ តុលាការបានឱ្យមេធាវីម្នាក់ឈ្មោះមៃសែរដើម្បីការពារ គាត់ ។ ប៉ុន្តែមេធាវីនេះមិនបានការពារគាត់ទេ ប៉ុន្តែបែរជាបន្ថែមទម្ងន់ទោស ឱ្យគាត់ទៀត ។ តើគាត់មានផ្លូវអ្វីនឹងជ្រើសរើសទៀត? បើគាត់គ្មានសាក្សី គ្មានសាច់ញាតិ និងថែមទាំងគ្មានមិត្តភក្តិម្នាក់សោះ ជាពិសេស គាត់គ្មានលុយ ១សេនសម្រាប់ជួលមេធាវីពូកែៗ ដើម្បីការពារខ្លួននោះ ។

រឿងជនរងគ្រោះ និពន្ធដោយលោកប្រ៊ីសេ វ៉ាល់តុន Bryce Walton ប្រែសម្រួលដោយបណ្ឌិតជា ណេង ។

**ហេង ដារី**

# អធិប្បាយព្រះបន្ទូលថ្ងៃអាទិត្យ



## ខែមីនា ២០១១ ដោយលោកបូជាចារ្យវ៉ាំងសង់ សេនីយ៍ឆាល

ខែមីនានេះ គ្រីស្តបរិស័ទចូលរដូវ ៤០ថ្ងៃ ដែលជារដូវមួយពិសេស។ យើងទាំងអស់គ្នាខិតខំអធិដ្ឋានតមអាហារ និងធ្វើទានឱ្យអ្នកដែលខ្វះខាត។ ចំពោះបងប្អូនដែលត្រៀមខ្លួនទទួលអគ្គសញ្ញាជ្រមុជទឹកនៅពេលរាត្រីបុណ្យចម្លងនោះវិញ រដូវនេះជាពេលវេលាដ៏សំខាន់ដែលបងប្អូនត្រូវទទួលការអប់រំពិសេស។ អត្ថបទគម្ពីរដំណឹងល្អ ក្នុងខែមីនា ជួយបងប្អូនទាំងនោះឱ្យយល់ច្បាស់អំពីអត្ថន័យនៃជីវិតជាគ្រីស្តបរិស័ទ។

**អាទិត្យទី៩ ក្នុងរដូវធម្មតា (ថ្ងៃទី០៦ ខែមីនា ២០១១)** *(ម៉ាថាយ ៧,២១-២៧)*

"អ្នកដែលចូលទៅក្នុងព្រះរាជ្យនៃស្ថានបរមសុខ មិនមែនជាអ្នកដែលគ្រាន់តែហៅខ្ញុំថា "ព្រះអម្ចាស់! ព្រះអម្ចាស់!" ប៉ុណ្ណោះទេ គឺអស់អ្នកដែលធ្វើតាមព្រះហឫទ័យរបស់ព្រះបិតាខ្ញុំ ដែលគង់នៅស្ថានបរមសុខវិញ"។ តាមព្រះបន្ទូលនេះ ព្រះយេស៊ូរំឭកយើងថា យើងត្រូវស្វែងយល់ពីព្រះហឫទ័យព្រះជាម្ចាស់ ហើយប្រតិបត្តិតាម។ តាមពិតបងប្អូនដែលទទួលការអប់រំជំនឿ កំពុងរៀនសូត្រដើម្បីយល់អំពីព្រះហឫទ័យព្រះជាម្ចាស់ គឺដើម្បីមានចំណេះអំពីព្រះអង្គ។ ចំណេះនេះពង្រឹងជំនឿរបស់បងប្អូន ហើយជំនឿនាំគេឱ្យប្រតិបត្តិតាម។ នេះមានន័យថា ជាការនាំបងប្អូនឱ្យប្រព្រឹត្តកិច្ចការដែលគាប់នឹងព្រះហឫទ័យព្រះអង្គ។ សរុបសេចក្តីទៅហាក់ដូចជាចំណេះអំពីព្រះជាម្ចាស់ ជំនឿលើព្រះអង្គ និងការប្រតិបត្តិ ជួយពង្រឹងគ្នាទៅវិញទៅមកក្នុងជីវិតរបស់បងប្អូន។ ព្រះយេស៊ូមានព្រះបន្ទូលត្រឹមត្រូវមែនដែលរំឭកយើងថា យើងត្រូវបង្ហាញជំនឿរបស់យើងឱ្យមនុស្សឃើញដោយអំពើល្អដែលយើងប្រព្រឹត្ត។

**អាទិត្យទី១ ក្នុងរដូវ៤០ថ្ងៃ (ថ្ងៃទី១៣ ខែមីនា ២០១១)** *ម៉ាថាយ (៤,១-១១)*

នៅក្នុងព្រះគម្ពីរសម្ព័ន្ធមេត្រីចាស់ វាលរហោស្ថាន ជាទីកន្លែងមួយដ៏សំខាន់។ ជនជាតិអ៊ីស្រាអែលបានធ្វើដំណើរក្នុងវាលរហោស្ថានអស់រយៈពេល ៤០ឆ្នាំ ដើម្បីចូលក្នុងទឹកដីដែលព្រះជាម្ចាស់បានសន្យា គឺស្រុកកាណាន។ នៅពេលនោះ ប្រជារាស្ត្ររបស់ព្រះជាម្ចាស់បានធ្វើដំណើរឆ្ពោះទៅកាន់សេរីភាព។ ពួកគេបានឈប់ពឹងផ្អែកលើម្ចាស់ម្នាក់ ដែលមានលក្ខណៈជាមនុស្ស (ស្តេចផារ៉ោន) ដើម្បីពឹងផ្អែកលើព្រះជាម្ចាស់អស់ពីដួងចិត្ត។ នៅវាលរហោស្ថាន ព្រះយេស៊ូបង្ហាញអំពីសេរីភាពដ៏ពិតប្រាកដ ដែលមកពីការពឹងផ្អែកលើព្រះបន្ទូលព្រះជាម្ចាស់។ ព្រះបន្ទូលជាទីពឹងដើម្បីឈ្នះការល្បួង ដែលយើងជួបប្រទះ។

**អាទិត្យទី២ ក្នុងរដូវ៤០ថ្ងៃ (ថ្ងៃទី២០ ខែមីនា ២០១១)** *ម៉ាថាយ (១៧,១-៩)*

លោកម៉ូសេ និងព្យាការីអេលី ទាំងពីររូប ជាតំណាងសម្ព័ន្ធមេត្រីចាស់ គឺតំណាងរបស់គម្ពីរធម្មវិន័យ និងគម្ពីរព្យាការី។ ព្រះយេស៊ូសន្ទនាជាមួយលោកទាំងពីរដើម្បីដឹងអំពីអនាគតកាលរបស់ព្រះអង្គតាមរយៈគម្ពីរធម្មវិន័យ និងគម្ពីរព្យាការី ទស្សន៍ទាយអំពីព្រះមេស្ស៊ី ជាពិសេសព្រះអង្គនឹងសោយទិវង្គតហើយទទួលសិរីរុងរឿងដែលមកពីព្រះជាម្ចាស់។ នៅពេលយើងអធិដ្ឋាន និងអានព្រះបន្ទូលព្រះវិញ្ញាណដ៏វិសុទ្ធអាចបំភ្លឺយើងឱ្យស្គាល់អំពីដំណើរជីវិតរបស់យើង។

**អាទិត្យទី៣ ក្នុងរដូវ៤០ថ្ងៃ (ថ្ងៃទី២៧ ខែមីនា ២០១១)** *ម៉ាថាយ (៤,៥-៤២)*

ព្រះយេស៊ូជួបស្ត្រីសាសន៍សាម៉ារីម្នាក់ដែលមានបញ្ហាច្រើនក្នុងជីវិត។ នេះជាមូលហេតុដែលនាំឱ្យស្ត្រីនេះមកដងទឹកនៅពេលថ្ងៃត្រង់ ពីព្រោះប្រហែលជានាងមិនសូវចង់ជួបអ្នកដទៃទេ។ នាងចូលចិត្តនៅតែម្នាក់ឯងដោយឡែកពីគេ ដ្បិតនាងខ្មាស់គេ ព្រោះខ្លួនធ្លាប់មានប្តីប្រាំមកហើយ។ ដើមដំបូងស្ត្រីនេះប្រកាន់ព្រះយេស៊ូដោយសារព្រះអង្គជាជនជាតិយូដា។ ក្រោយមកនាងមានសំណួរ ជាច្រើនអំពីរបៀបថ្វាយបង្គំព្រះជាម្ចាស់។ ព្រះយេស៊ូពន្យល់គាត់អំពីការថ្វាយបង្គំដ៏ពិតប្រាកដ គឺថ្វាយបង្គំព្រះជាម្ចាស់ជាព្រះបិតាតាមព្រះវិញ្ញាណដ៏វិសុទ្ធ។ ព្រះអង្គអប់រំគាត់អំពីពិធីជ្រមុជទឹកដែលបំពេញចិត្តមនុស្សដែលស្វែងរកព្រះជាម្ចាស់។ ជាលំដាប់នាងទទួលស្គាល់ថា ព្រះយេស៊ូជាព្រះគ្រីស្ត និងជាព្រះសង្គ្រោះរបស់មនុស្សលោក។ ចំពោះអស់បងប្អូនដែលត្រៀមខ្លួនទទួលអគ្គសញ្ញាជ្រមុជទឹកគួរចាប់អារម្មណ៍នឹងការអប់រំរបស់ព្រះយេស៊ូដល់ស្ត្រីសាម៉ារី។

## កំណាព្យ

### ទំនួញអប្សរា (បទគោព័ន្ធស្ទឹង)

១-អ្នកមានជីវិតឋិតលើលោក
ដីមានជីវជាតិលាតធំក្រៃ
២-សម្បូរសម្បត្តិសត្វឈើផង
អូរតូចអូរធំជុំទឹកហូរ
៣-តន្ត្រីពីរោះទ្រគោះលាយ
កវីដែរឆ្នើមឆ្នើមសំដី
៤-ទំនុកទួញសោកបោកអក្ខរា
ទុក្ខអើយទុក្ខខ្ញុំក្រំណែនចុក
៥-ព្រានអាងអំណាចកាចឫស្យា
អៀនអស់ធម្មជាតិញាតិព្រៀងលាន

លោកនេះគគោកលើផែនដី
ក្រៃដូចចរណៃផ្តុំសម្បូរ។
ផងផែនកន្លងព្រៃដងអូរ
ហូរលាន់ជាស្នូរតូរ្យតន្ត្រី។
លាយឡំសំពាយនាយកវី
សំដីមានន័យរាយទំនុក។
អក្ខរាថែងចារសិលាទុក្ខ
ចុកចាប់មិនសុខព្រោះតែព្រាន។
ឫស្យាប្រហារមិនខ្មាសអៀន
លានលោភបំពានគ្មានមេត្តា។

៦-មេត្តាអប្សរាចារយូរលង់
ធីតាល្អឯកប្លែកអស្ចារ្យ
៧-ខ្មែរមានឈាមជ័រអ្នកតស៊ូ
ភ្លេរតែមនុស្សពាលគ្មានឈាមខ្មែរ
៨-ប្រាកដកំណត់ដូចចម្លាក់
បទមើលរូបរាងគួរកំសត់
៩-ពិតណាស់ឃើញច្បាស់ព្រះសិរសា
អាណិតចម្លាក់ល្អវិចិត្រ

លង់ស្រស់ឆោមយង់ទេពធីតា
អស្ចារ្យស្នាដៃបុរសខ្មែរ។
ស៊ូស្លាប់ហ៊ានប្តូរឥតខ្លាញ់ខ្លែរ
ខ្មែរពិតអ្នកស្នេហ៍ជាតិប្រាកដ។
ចម្លាក់បាត់បាក់គ្រប់បែបបទ
កំសត់ព្រោះអត់រូបរាងពិត។
សាសព្វកាយាសែនអាណិត
ចិត្តស្តាយកាយគិតចង់សងសឹក។



អ្នកស្រី
ខុង ណារី

**និពន្ធដោយអ្នកស្រី ខុង ណារី**
**រៀបរៀងដោយលោក ឡុង សុផល។**

# ពិធីព្រះព្រំភូមិនៅព្រះសហគមន៍ចំណោម ភូមិបាត់ដំបង

លី សុវណ្ណា









## បុរីវ៉ាទីកង់

### សម្តេចប៉ាបបេនេឌីកទី១៦ សូមឱ្យរិះគិតស៊ីជម្រៅអំពីអគ្គសញ្ញាជ្រមុជទឹក

សម្តេចប៉ាបបេនេឌីក ទី១៦ បានស្នើសុំឱ្យព្រះសហគមន៍រិះគិតឱ្យបានស៊ីអំពីអគ្គសញ្ញាជ្រមុជទឹកក្នុងរដូវអប់រំពិសេសនេះ។

យោងទៅតាមសារលិខិតរបស់សម្តេចប៉ាបប្រចាំរដូវអប់រំពិសេស កាលពីថ្ងៃទី២២ ខែកុម្ភៈ កន្លងទៅនេះ សម្តេចប៉ាបបេណេឌីក ទី១៦ បានមានប្រសាសន៍ថា: "បងប្អូនទទួលពិធីជ្រមុជទឹក បងប្អូនត្រូវកប់ក្នុងផ្នូររួមជាមួយព្រះគ្រីស្ត ហើយបងប្អូនក៏ទទួលជីវិតថ្មីរួមជាមួយព្រះអង្គដែរ"។ សម្តេចប៉ាបបេនេឌីកទី១៦ បានមានប្រសាសន៍បែបនេះ នៅក្នុងសាររបស់សម្តេចសម្រាប់រដូវអប់រំពិសេសឆ្នាំនេះ។

តាមរយៈសារលិខិតនេះ សម្តេចប៉ាបបានឱ្យដឹងថា នេះគឺជាការតភ្ជាប់មួយរវាងអគ្គសញ្ញាជ្រមុជទឹក និងរដូវអប់រំពិសេស ដែលជាពេលវេលា និងជាបទពិសោធន៍ដ៏មានតម្លៃរបស់ព្រះសហគមន៍។ សម្តេចប៉ាបមានប្រសាសន៍ថា ពិធីជ្រមុជទឹកនៅកុមារភាព គឺជាអំណោយទានរបស់ព្រះជាម្ចាស់។ គ្មាននរណាម្នាក់អាចទទួលជីវិតអស់កល្បជានិច្ចដោយការខំប្រឹងប្រែងផ្ទាល់ខ្លួនឯងនោះទេ គឺត្រូវពឹងផ្អែកលើព្រះជាម្ចាស់។

សម្តេចមានប្រសាសន៍បន្តថា ធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ បានដកបាបចេញពីមនុស្ស នៅក្នុងពេលនោះដែរ នាំឱ្យយើងបានទទួលព្រះយេស៊ូផ្ទាល់ក្នុងជីវិតប្រចាំថ្ងៃរបស់ខ្លួនដោយមានសេរីភាព។

សម្តេចបញ្ជាក់ថា អគ្គសញ្ញាជ្រមុជទឹកនាំឱ្យគ្រីស្តបរិស័ទរួមស្លាប់រួមរស់ជាមួយព្រះគ្រីស្ត ដែលសោយទិវង្គត និងទទួលព្រះជន្មរស់ឡើងវិញ។ អគ្គសញ្ញាជ្រមុជទឹក មិនមែនជាពិធីបុណ្យពីបុរាណទេ តែអគ្គសញ្ញាជ្រមុជទឹកធ្វើឱ្យអ្នកជឿជួបនឹងព្រះគ្រីស្ត ដែលព្រះអង្គប្រែការរស់នៅរបស់គេក្នុងគ្រប់វិស័យ ឱ្យមានសភាពថ្មី។ ព្រះគ្រីស្តប្រទានព្រះជន្មផ្ទាល់របស់ព្រះបិតាឱ្យអ្នកជឿ ហើយក៏ត្រាស់ហៅគេឱ្យប្រែចិត្តគំនិត ដោយស្មោះ ដោយមានព្រះបិតាប្រណីសណ្តោសជំរុញគេ និងគាំទ្រគេ ឱ្យទៅជាមនុស្សពេញវ័យរួមជាមួយព្រះគ្រីស្ត។

Zenit.org

---

## វិទ្យុវ៉េរីតាស់អាស៊ី (RVA)

Radio Veritas Asia

Crossing Borders, Sharing Christ

**ផ្នែកភាសាខ្មែរផ្សាយរយៈពេល ៥៧នាទី**

**ជារៀងរាល់ថ្ងៃតាមរយៈ រលកធាតុអាកាសខ្លី**

**(Short Wave = sw) គឺ :**

~ពេលរសៀល ពីម៉ោង ៥:០០នាទី ដល់ម៉ោង ៥:៣០នាទី ផ្សាយក្នុងរលកធាតុអាកាស

១១៨៥០ គីឡូហឺតស៍ ត្រូវនឹងកម្ពស់ ២៥,៣២ ម៉ែត្រ។

ស្តាប់វិទ្យុវ៉េរីតាស់ អាស៊ី (RVA) លោកអ្នកនឹងទទួលបានចំណេះដឹងទូទៅជាច្រើនទាក់ទង

នឹងជីវិតរស់នៅប្រចាំថ្ងៃ និងសង្គម និងព័ត៌មាននានាពីព្រះសហគមន៍កាតូលិកនៅកម្ពុជា។

## ការងារប្រចាំខែ

- ថ្ងៃ៥-៦ មីនា : នៅព្រះសហគមន៍បឹងទំពុន មានរៀបចំសិក្ខាសាលាលើប្រធានបទ "គ្រីស្តបរិស័ទមានតម្លៃក្នុងសង្គម"។
- ថ្ងៃ០៨ មីនា : បងស្រីលក្ខិណាធ្វើសំណាក់ធម៌ខាងអប់រំជំនឿ និងស្វែងរកយុទ្ធសាស្ត្របង្រៀនកុមារនៅព្រះសហគមន៍សៀមរាប។
- ថ្ងៃ១២ មីនា : គ្រីស្តបរិស័ទ ៣១នាក់ ដែលមកពីព្រះសហគមន៍កំពត សំណាក់ធម៌មួយថ្ងៃជាមួយលោកអភិបាល នៅព្រះវិហារសន្តយ៉ូសែប (ផ្សារតូច) ទីក្រុងភ្នំពេញ។
- ថ្ងៃ១៣ មីនា : ពិធីទទួលជំហានទីពីរនៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញនៅព្រះវិហារសន្តយ៉ូសែប (ផ្សារតូច)ក្រុងភ្នំពេញ។
- ថ្ងៃ១៨-២៦ មីនា: ព្រះសហគមន៍សៀមរាបក្នុងរដូវអប់រំពិសេសរៀបចំកម្មវិធីផ្សេងៗ ដូចជាដើរផ្លូវឈើឆ្កាង សម្តែងអំពីទុក្ខលំបាករបស់ព្រះយេស៊ូ និងធ្វើអភិបូជា... ដែលមានការចូលរួមពីភ្ញៀវសិង្ហបុរី ៣០នាក់។
- ថ្ងៃទី២២-២៥ មីនា : ដំណើរទស្សនកិច្ចរបស់លោកអគ្គរាជទូតនៅប្រទេសកម្ពុជា។
- ថ្ងៃ២៥-២៧ មីនា : នៅព្រះសហគមន៍កំពង់ចាម មានរៀបចំសិក្ខាសាលាលើប្រធានបទ "គ្រីស្តបរិស័ទមានតម្លៃក្នុងសង្គម"។
- ថ្ងៃ២៥-២៧ មីនា : ប្រជុំលើកទីពីររបស់យុវជនដើម្បីរៀបចំចូលរួមទិវាយុវជនពិភពលោក (World youth's day) នៅប្រទេសអេស្ប៉ាញដោយចូលរួមពីយុវជន ៣២នាក់ នៅព្រះសហគមន៍កំពង់ចាម។
- ថ្ងៃ២៦-២៧ មីនា : នៅសាលាដុនបូស្កូ ទឹកថ្លា(ស្រី) រាជធានីភ្នំពេញ មានការប្រជុំលើកទី២ សម្រាប់ក្រុមអេម៉ាណូអែល ប្រមាណជិត ២០នាក់ ក្រោមប្រធានបទ "ប្រវត្តិព្រះសហគមន៍"។


**ការិយាល័យព័ត៌មានកាតូលិក**

ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់ បឹងព្រលិត ខណ្ឌ ៧ មករា រាជធានី ភ្នំពេញ

Tel/Fax : (855) 23 224 120;

E-mail : csccambodia@gmail.com

Website : www.catholiccambodia.org

អ្នកសម្របសម្រួល : លោកស្រីប្រាម៉ុង វីរៈជ័យ។ ប្រធាន : លោកលី សុវណ្ណា។

Licence ១៨៣ ពម.ប្រក. / ២៥-មិថុនា-២០០៧